**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អត្ថិភាព និង នត្ថិភាពនៃសន្តតិជន

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **ក. មាស ចំណូល**
**ក. អេង ណៃស៊ីម**

សាស្ត្រាចារ្យណែនាំ
លោកបណ្ឌិត **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៤ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អត្ថិភាព និង នត្ថិភាពនៃសន្តតិជន

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **ក. មាស ចំណូល**
**ក. អេង ណៃស៊ីម**

សាស្ត្រាចារ្យណែនាំ
លោកបណ្ឌិត **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៤ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **មាស ចំណូល** និង **អេង ណៃស៊ីម** ជានិស្សិតឆ្នាំទី៤ ថ្នាក់$L_4B_1$ នៃថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ ថ្នាក់អាហារូបករណ៍ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៥-២០១៩។

## សូមគោរព និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកឪពុក** និង **អ្នកម្តាយ** ដែលបានខិតខំចិញ្ចឹមបីបាច់ថែរក្សាការពារតាំងពីនៅក្នុងគភ៌រហូតដល់ធំ។ ក្រៅពីនេះលោកទាំងពីរបានជួយទំនុកបំរុងដល់ពួកយើងក្នុងការសិក្សារៀនសូត្រដើម្បីក្រេបយកនូវចំណេះដឹងដ៏ភ្លឺស្វាង ដែលលោកទាំងពីរគឺជាទីគោរព និង ជាទីស្រលាញ់របស់កូនៗ។ លោកទាំងពីរបានទូន្មានប្រៀនប្រដៅ និង អប់រំពួកយើងឲ្យក្លាយជាកូនល្អ សិស្សល្អ និង ជាពលរដ្ឋល្អនៅក្នុងសង្គម រហូតដល់ពួកយើងបានឈានដល់គោលដៅមួយនេះ។

ក្រៅពីនេះ សូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងការផ្តល់ចំណេះដឹងដល់និស្សិតគ្រប់រូបដោយមិនលំអៀង ហើយបានយកចិត្តទុកដាក់ឲ្យនិស្សិតទទួលបានចំណេះវិជ្ជា និង បទពិសោធន៍ជាច្រើន ដែលនាំឲ្យនិស្សិតទទួលបានអនាគតដ៏ល្អនៅថ្ងៃមុខ។

## យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលឯកឧត្តមជាថ្នាក់ដឹកនាំដ៏ល្អ បានផ្តល់ឱកាសឲ្យនិស្សិតគ្រប់មជ្ឈដ្ឋានទទួលបានឱកាស និង បានចូលរៀននៅក្នុងសាកលវិទ្យាល័យដែលមានកិត្តិនាមល្បីល្បាញមួយនេះ។

**លោកបណ្ឌិត ព្រុំ រិទ្ធី** ជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ដែលលោកបណ្ឌិតបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ណែនាំ និងផ្តល់ជាអនុសាសន៍ក្នុងការកែតម្រូវដើម្បីឲ្យសារណាមួយនេះបញ្ចប់ទៅដោយភាពជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមជូនពរដល់អ្នកមានគុណទាំងអស់គ្នាទទួលបានសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានសិក្សាអស់រយៈពេលបួនឆ្នាំនៃផ្នែកនីតិសាស្ត្រនេះមក យើងខ្ញុំបានកត់សម្គាល់នូវមុខវិជ្ជាទាក់ទងនឹងសន្តតិកម្មដែលជាទីចាប់អារម្មណ៍ រហូតដល់យើងខ្ញុំធ្វើការស្រាវជ្រាវទាក់ទងនឹងសន្តតិកម្មនេះដើម្បីបង្កើតនូវប្រធានបទថ្មីមួយស្តីអំពី "**អត្ថិភាព និង នត្ថិភាពនៃសន្តតិជន**" គឺជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដែលបានខិតខំសហការគ្នាស្រាវជ្រាវ និង ចងក្រងឡើង ដើម្បីជាចំណែកមួយនៃចំណេះដឹងសម្រាប់ឲ្យនិស្សិតជំនាន់ក្រោយអាចធ្វើការពិភាក្សាវែកញែកបាន។

ប្រធានបទមួយនេះ ចង់ឆ្លុះបញ្ចាំងអំពីទិដ្ឋភាពមួយដែលមតកជនកាលនៅរស់គ្មានក្រុមគ្រួសារសាច់ញាតិ ឬ បានបែកបាក់ ព្រាត់ប្រាសគ្នាមិនដឹងនៅទីណា រហូតដល់ពេលដែលជននេះទទួលមរណភាពហើយមតិកដែលជននេះនៅមានមិនដឹងរៀបចំ និង ត្រូវឲ្យអ្នកណា។ ដូច្នេះគេត្រូវរកអ្នកដែលមានលក្ខណៈសម្បត្តិជាសន្តតិជនពិតប្រាកដដែលស្របតាមច្បាប់ មកទទួលនូវសិទ្ធិ និងកាតព្វកិច្ចបន្តពីមតកជន ដែលនេះគឺជាការបញ្ជាក់អំពីអត្ថិភាព និង អំពីនត្ថិភាព។

យើងខ្ញុំទាំងពីរនាក់ពិតជារីករាយក្នុងការខិតខំ ស្វះស្វែងរកនូវឯកសារទាំងឡាយ ព្រមទាំងកម្រងច្បាប់គតិយុត្តនានាដែលទាក់ទិនអំពីប្រធានបទខាងលើនេះណាស់ ហើយវាក៏ជាផ្នែកមួយក្នុងការទទួលបានចំណេះដឹងបន្ថែមទៀតសម្រាប់ខ្លួនយើងខ្ញុំផ្ទាល់ ក៏ដូចជាអ្នកអាន និង និស្សិតទាំងអស់។

យើងខ្ញុំសូមអរគុណដល់ **លោកបណ្ឌិត ព្រុំ រិទ្ធី** ដែលបានបង្រៀន និង ជួយណែនាំដល់យើងខ្ញុំ ដើម្បីធ្វើឲ្យសារណាមួយនេះមានដំណើរការទៅបានរលូន និង បានសម្រេចដោយជោគជ័យ។ ក្រៅពីនេះក៏សូមអរគុណដល់ដៃគូសរសេរសារណាដែលបានជួយ សហការគ្នាទៅបានល្អ និង ប្រកបទៅដោយមិត្តភាព។

យើងខ្ញុំក៏សូមអភ័យទោសផងដែរ នូវរាល់ការកង្វះខាតណាមួយ និង ការធ្វេសប្រហែសដោយអចេតនាពីយើងខ្ញុំទាំងអស់គ្នា ប្រសិនបើមានការខ្វះខាត មិនគ្រប់គ្រាន់ សូមអភ័យទោសពីយើងខ្ញុំទាំងអស់គ្នាផង។

ជាទីបញ្ចប់ យើងខ្ញុំរីករាយ និង ទទួលស្វាគមន៍ជានិច្ច ចំពោះការទិះតៀនផ្សេងៗពីអ្នកទាំងអស់គ្នា។

# មាតិកា


**ទំព័រ**

**សេចក្ដីផ្ដើម** ..... ១

**ជំពូកទី១៖ នីតិវិធីស្វែងរកសន្តតិជន** ..... ៤

១.១. ដំណាក់កាលទី១៖ ការជ្រើសតាំងអ្នកគ្រប់គ្រង ..... ៥

១.២. ដំណាក់កាលទី២៖ ការជូនដំណឹងជាសាធារណៈលើកទី១ ដោយតុលាការ ..... ៥

១.៣. ដំណាក់កាលទី៣៖ ការជូនដំណឹងជាសាធារណៈលើកទី២ ដោយអ្នកគ្រប់គ្រង ..... ៥

១.៤. ដំណាក់កាលទី៤៖ ការជូនដំណឹងជាសាធារណៈលើកទី៣ ដោយតុលាការ ..... ៦

**ជំពូកទី២៖ អត្ថិភាព** ..... ៨

២.១. លក្ខណៈនៃអត្ថិភាព ..... ៩

២.១.១. លក្ខណៈសម្បត្តិជាសន្តតិជន ..... ៩

២.១.១.១. បុគ្គលដែលមានជីវិតរស់នៅ ..... ៩

២.១.១.២. បុគ្គលដែលមិនឋ្លោះសិទ្ធិជាសន្តតិជន ..... ១០

ក. ជនមិនមែនជាអភ័ព្វបុគ្គល ..... ១០

ខ. បុគ្គលដែលមិនបានផ្ដាច់មត៌កចេញពីសន្តតិកម្ម ..... ១១

២.១.២. បុគ្គលមានសិទ្ធិជាសន្តតិជន ..... ១១

២.១.២.១. សន្តតិជនតាមច្បាប់ ..... ១១

២.១.២.២. សន្តតិជនជំនួស ..... ១៣

២.១.២.៣. សន្តតិជនជាសហាព័ទ្ធ ..... ១៣

២.២. ការទទួលស្គាល់សន្តតិកម្ម ..... ១៤

២.២.១. ការយល់ព្រមទាំងស្រុង ..... ១៥

២.២.២. ការយល់ព្រមដោយកម្រិត ..... ១៥

២.៣. អត្ថិភាពធ្វើឲ្យរលត់សិទ្ធិរបស់អ្នកគ្រប់គ្រង ..... ១៦

២.៤. ការធ្វើបដិទានសន្តតិកម្ម ..... ១៦

**ជំពូកទី៣៖ នត្ថិភាព** ............ ១៨
៣.១. លក្ខណៈនៃនត្ថិភាព ............ ១៨
៣.១.១. ការបាត់បង់សិទ្ធិជាសន្តតិជន ............ ១៨
៣.១.១.១.បុគ្គលដែលផ្លោះសិទ្ធិជាសន្តតិជន ............ ១៩
ក. អភ័ព្វបុគ្គល ............ ១៩
ខ. ការផ្តាច់មតិកចេញពីសន្តតិកម្ម ............ ២០
៣.២. ការបោះបង់សន្តតិកម្ម ............ ២២
៣.២.១. ការបោះបង់សន្តតិកម្ម ............ ២២
៣.២.១. នីតិវិធីនៃការបោះបង់ ............ ២៣
៣.៣. ការចាត់ចែងមតិក ............ ២៣
៣.៣.១. សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកគ្រប់គ្រង ............ ២៣
៣.៣.២. កម្រៃសម្រាប់អ្នកគ្រប់គ្រង ............ ២៤
៣.៣.៣. នត្ថិភាពមិនធ្វើឲ្យរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ............ ២៥
៣.៣.៤. ការចាត់ចែងទ្រព្យទៅឲ្យជនមានិស្ស័យពិសេស ............ ២៥
៣.៣.៥. មតិកធ្លាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ ............ ២៦
៣.៤. ករណីនត្ថិភាពនៃសន្តតិជននៅសហរដ្ឋអាមេរិក ............ ២៧
**សេចក្តីសន្និដ្ឋាន** ............ ៣១
**អនុសាសន៍** ............ ៣៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

របបសន្តតិកម្មនៅប្រទេសកម្ពុជា ត្រូវបានអនុវត្តតាំងតែពីបុរាណកាលមក ដោយអ្នកជំនាន់មុនបានរៀបចំ និង ចាត់ចែងអំពីទ្រព្យរបស់ខ្លួនទៅតាមទំនៀមទម្លាប់ខ្មែរពីបុរាណ។ ឧទាហរណ៍ជាក់ស្តែងនៅក្នុងរឿងព្រេងខ្មែរ រឿង"កូន៤នាក់មិនបម្រើឪពុក" បានបង្ហាញឲ្យឃើញពីរបៀបនៃការបែងចែកទ្រព្យកាលពីសម័យបុរាណដែរ គឺកាលពីឪពុកនៅរស់ឪពុកបានចែកមតិករបស់គាត់ទៅឲ្យកូនទាំង៤រៀងៗខ្លួន ក្រោយមកបន្ទាប់ពីបុរសជាឪពុកបានស្លាប់បាត់ទៅកូនទាំង៤នាំគ្នាធ្វើបុណ្យអធិកអធមតាមទំនៀមទម្លាប់ហើយក៏នាំគ្នាគាស់ពាងដែលជាកំណប់ចុងក្រោយរបស់ឪពុក (ដោយពុំដឹងថា នេះជាល្បិចកុហកឪពុករបស់ខ្លួន ហើយគាត់បានចែកចំណែកមតិករៀងៗខ្លួនអស់រួចទៅហើយកាលនៅរស់) ដើម្បីបើកសន្តតិកម្មដែលនៅសល់[1]។ ទោះជាយ៉ាងនេះក្តី ក៏របបសន្តតិកម្មក៏មានការកែប្រែទៅតាមរបបសង្គមនីមួយៗ និង តាមសម័យកាលខុសៗគ្នា។

កាលពីសម័យបុរាណព្រះរាជាតែងតែធ្វើព្រះរាជបណ្តាំទុកមុនពេលដែលទ្រង់បានសោយទីវង្គតដើម្បីជ្រើសរើស ឬ តែងតាំងព្រះរាជបុត្រណាមួយជារជ្ជទាយាទស្នងរាជ្យបន្តពីព្រះអង្គ។ ចំណែកឯនាម៉ឺនមន្ត្រីវិញនៅពេលទទួលមរណភាព កូនរបស់ខ្លួនជាអ្នកស្នងតំណែងបុណ្យសក្តិបន្តពីឪពុក ជាក់ស្តែងក្នុងរឿងព្រេងខ្មែរ គឺរឿង "តេជោយ៉ត" ដែលមានតួអង្គតេជោមាសជាមេទ័ពដ៏ខ្លាំងពូកែ និង មានកូនសិស្សជំនិតគឺ យ៉ត ហើយតែងតែទៅធ្វើសង្គ្រាមជាមួយគ្នា លុះពេលដែលតេជោមាសទទួលមរណភាពទៅ យ៉តបានទទួលតំណែងជាមេទ័ព ដែលមានតួនាទីដឹកនាំកងទ័ពជំនួសតេជោមាស។ អត្ថន័យនៃរឿងនេះ គឺបង្ហាញថា តេជោយ៉តបានស្នងតំណែងបុណ្យសក្តិបន្តពីតេជោមាសដែលជាគ្រូរបស់ខ្លួនដែលប្រៀបបីដូចជាឪពុកបង្កើត ព្រោះតេជោមាសពុំមានកូនឡើយហើយមានតែយ៉តម្នាក់គត់ដែលគាត់ស្រលាញ់និងទុកចិត្តដូចកូនបង្កើត ថ្វីបើតេជោយ៉តជាកូនសិស្សពិតមែន តែយ៉តបានរស់នៅនិងហាត់រៀនពីតេជោមាសតាំងពីតូច ធ្វើឲ្យទំនាក់ទំនងអ្នកទាំងពីរប្រៀបដូចជាឪពុកនឹងកូន[2]។

ជាពិសេសសម័យបុរាណគ្មានច្បាប់ចែងពីការបែងចែកទ្រព្យឲ្យច្បាស់លាស់នាសម័យនោះឡើយ គឺពុំទាន់មានទំនៀមទម្លាប់ក្នុងការបែងចែកទ្រព្យទៅឲ្យបុគ្គលដែលជាសហព័ទ្ធនៅឡើយទេ មានតែការបែងចែកទ្រព្យទៅឲ្យកូនដែលជាសន្តតិជនតែមួយគត់នៅក្នុងរបបសន្តតិកម្មសម័យបុរាណ ហើយក៏គ្មានច្បាប់សរសេរដែលបានចែងពីរបៀបនៃការបែងចែកទ្រព្យឡើយ។

---

[1] បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើមដោយគ្រឹះស្ថានបោះពុម្ព និង ចែកចាយនៃក្រសួងអប់រំ យុវជន និង កីឡា, *ប្រជុំរឿងព្រេងខ្មែរ ភាគទី៤,* (ភ្នំពេញ៖ អប់រំ, ២០០១), ១៤-១៨។

[2] ទី ជីហួត, *រឿងតេជោយ៉ត,* បោះពុម្ពលើកទី២ (ភ្នំពេញ៖ ស្រី ប៊ុនដន, ២០០៥)។

ការអនុវត្តបែបនេះបន្តៗគ្នាពីសម័យកាលមួយទៅសម័យកាលមួយរហូតដល់បច្ចុប្បន្ននេះ ហើយ ទើបធ្វើឲ្យមានការសរសេរតាក់តែងឲ្យមានជាច្បាប់បានលេចឡើងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ បានកែប្រែពីទំនៀមទម្លាប់ប្រពៃណីមកជាការអនុវត្តតាមច្បាប់ដោយយល់ឃើញថា ការបែងចែកទ្រព្យសម័យបុរាណពុំមានមូលដ្ឋានច្បាស់លាស់ហើយជាពិសេសឃើញថាការបែងចែកមតិកនៅក្នុងសម័យកាលនីមួយៗធ្វើឲ្យមានភាពមិនស្មើគ្នាឡើយរវាងសន្តតិជនទាំងអស់នៅក្នុងរបបសន្តតិកម្ម ព្រោះមតកជនធ្វើការបែងចែកមតិកឲ្យទៅសន្តតិជនទៅតាមអារម្មណ៍ដែលខ្លួនបានគិតប៉ុណ្ណោះថាគួរឲ្យទៅកូនដែលជាសន្តតិជនរូបណាមានសមត្ថភាព ឬ ជាកូនដែលខ្លួនស្រលាញ់ជាងគេ គឺឃើញថាមានភាពលំអៀងទៅលើសន្តតិជនផ្សេងៗទៀតដែលមិនទទួលបានអ្វីសោះឡើយ។

ដោយសារការផ្លាស់ប្តូររបបនយោបាយឥតឈប់ឈរធ្វើឲ្យវិស័យគតិយុត្តនៅប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងដោយសារសង្គ្រាម។ ជាក់ស្តែង នៅឆ្នាំ១៩៧៥ ដល់ ១៩៧៩ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងរបបដ៏ខ្មៅងងឹត ដែលត្រូវបានគេទទួលស្គាល់ថា ជារបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសម័យនោះ ទ្រព្យសម្បត្តិឯកជនទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ដោយប្រជាពលរដ្ឋទេ ហើយគ្មានកម្មសិទ្ធិផ្ទាល់ខ្លួន គ្មានការផ្ទេរ គ្មានការកាន់កាប់ គ្មានការបើកសន្តតិកម្មអ្វីទាំងអស់។ ចាប់តាំងពីក្រោយការដួលរលំនៃរបបខ្មែរក្រហមមកប័ណ្ណកម្មសិទ្ធិដែលមានពីមុនត្រូវបានលុបបំបាត់ចោលទាំងអស់ព្រោះរដ្ឋពុំទាន់មានប្រព័ន្ធដីធ្លីច្បាស់លាស់ ហើយរបបថ្មីបានប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញដំបូងដោយក្រឹត្យលេខ០១ ក្រ ចុះថ្ងៃទី២៥ខែមិថុនា ឆ្នាំ១៩៨១ អនុលោមតាមមាត្រា១៤ ដីធ្លីទាំងអស់ជាកម្មសិទ្ធិរបស់រដ្ឋ ចំណែកឯពលរដ្ឋមានសិទ្ធិក្នុងការប្រើប្រាស់ និង មានសិទ្ធិតំណមតិកលើដី ដែលរដ្ឋប្រគល់ឲ្យគ្រួសារនីមួយៗតាមការកំណត់របស់ច្បាប់ ដើម្បីសង់ផ្ទះនៅ និង ធ្វើជាសួនច្បារសួនបន្លែ (មាត្រា១៥)។ ក្រៅពីដីសម្រាប់សង់លំនៅដ្ឋាន ដីសម្រាប់ធ្វើជាសួនច្បារ សួនបន្លែ និង ដីដែលក្រុមសាមគ្គីបង្កបង្កើនផលប្រគល់ឲ្យសម្រាប់បំពេញផលិតផលរបស់ក្រុមពលករ កសិករមួយរូបៗអាចធ្វើទៅបានដោយរដ្ឋឲ្យខ្ចីបន្ថែម ដើម្បីដាំដំណាំរដូវតាមលទ្ធផលនៃការងារនេះ[3]។

ដូចនេះប្រជាពលរដ្ឋម្នាក់ៗពុំមានកម្មសិទ្ធិឯកជនលើដីធ្លីទេ ពោលគឺត្រឹមតែសិទ្ធិប្រើប្រាស់ផ្ទាល់ខ្លួន និង សិទ្ធិអាស្រ័យផលធម្មជាតិលើដីធ្លី ដែលរដ្ឋចែកឲ្យតាមគ្រួសារតែប៉ុណ្ណោះ។ ច្បាស់ជាងនេះទៅទៀត ជនណាក៏ដោយគ្មានសិទ្ធិទិញលក់ បញ្ចាំ ឬ ប្រវាស់ដីធ្លីបានឡើយ ហើយក៏មិនអាចប្រើប្រាស់ដីធ្លី កសិកម្ម ដីព្រៃ ដោយចិត្តឯងក្នុងគោលបំណងផ្សេងទៀតបានឡើយប្រសិនបើគ្មាន

[3] ហែល ចំរើន, *វិវាទដីធ្លីនៅកម្ពុជា*, រកបាននៅសៀវភៅ វស្សបវត្តិ (បោះពុម្ពផ្សាយដោយការឧបត្ថម្ភពីក្រុមសហប្រតិបត្តិការសកម្មភាពវប្បធម៌របស់ស្ថានទូតបារាំង ២០០៧),៤៨។

ការអនុញ្ញាតពីក្រសួងដែលមានសមត្ថកិច្ចទេនោះ[4]។ ហេតុនេះហើយបានជាការអនុវត្តរបបសន្តតិកម្ម គ្រាន់តែធ្វើការផ្ទេរពីឪពុកម្តាយដែលបានរស់នៅលើដីនោះឲ្យកូនរបស់ខ្លួន ហើយគ្មានការបែងចែក តាមលំដាប់សន្តតិជនទៅតាមភាគដែលត្រូវទទួលឡើយ តុលាការបានធ្វើការបែងចែកមតិកទៅតាម ភាពជាក់ស្តែងនៅក្នុងសង្គមដោយពឹងផ្អែកលើគោលការណ៍សមធម៌តែប៉ុណ្ណោះគ្មានមូលដ្ឋាន ច្បាស់លាស់នោះទេ។

រហូតដល់ឆ្នាំ១៩៨៩ ការកម្រិតសិទ្ធិរបស់ពលរដ្ឋលើដីធ្លីខាងលើត្រូវបានបន្ធូរបន្ថយជាច្រើន ប្រការដោយវិសោធកម្មរដ្ឋធម្មនុញ្ញដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ១៤ ក្រ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៩ ដែលបង្ហាញឲ្យឃើញឆន្ទៈដោយប្រយោលរបស់កម្ពុជា ក្នុងដំណើរការទទួលស្គាល់សិទ្ធិ កម្មសិទ្ធិឯកជនទទួលស្គាល់លើដីធ្លី កម្មសិទ្ធិរបស់រដ្ឋត្រូវបានលុបបំបាត់ រហូតដល់មានការបង្កើត ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ១៩៨៨ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ១៩៨៩ ការវិវត្តន៍សន្សឹមៗនៃការផ្លាស់ប្តូរដោយមានការកំណែទម្រង់ច្បាប់ជាបន្តបន្ទាប់នាំ ឲ្យមានការបង្កើតច្បាប់ភូមិបាលនៅឆ្នាំ២០០១ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ និង អមដោយអនុក្រឹត្យ ព្រមទាំងប្រកាសនិងសារាចរណែនាំខ្លះៗផ្សេងៗទៀតរបស់ ក្រសួងយុត្តិធម៌ បានលុបចោលនូវមន្ទិលសង្ស័យទាំងប៉ុន្មានជុំវិញបញ្ហាតម្លៃគតិយុត្តិនៃប័ណ្ណសម្គាល់ ម្ចាស់កម្មសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនេះ ដោយធ្វើការបែងចែកច្បាស់លាស់នូវប្រភេទប័ណ្ណជាពីរគឺ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ត្រូវចេញចំពោះដីភោគៈ និង វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលវត្ថុ ត្រូវចេញចំពោះដីម្ចាស់កម្មសិទ្ធិ គឺបានអនុញ្ញាតឲ្យមានការផ្ទេរកម្មសិទ្ធិ មិនមែនផ្ទេរកម្មសិទ្ធិកាន់កាប់ តាមប្រពៃណីទៀតនោះទេគឺផ្ទេរស្របតាមគតិយុត្ត[5]។

ក្រោយមក ច្បាប់ត្រូវបានបង្កើតឡើងឲ្យមានចែងយ៉ាងច្បាស់អំពីនីតិវិធីនៃការបែងចែកទ្រព្យ ក្នុងការវិវត្តពីមួយជំនាន់ទៅមួយជំនាន់ធ្វើឲ្យប្រទេសកម្ពុជាមានមានការរីកចម្រើនផ្នែកច្បាប់ជាលំដាប់ រហូតដល់បង្កើតឲ្យមានក្រមរដ្ឋប្បវេណីចុងក្រោយបង្អស់នៅឆ្នាំ២០០៧ ត្រូវបានបង្កើតឡើងក្រោម ជំនួយរបស់ប្រទេសជប៉ុន ក្រោមកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងក្រសួងយុត្តិធម៌ និង ទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនហៅកាត់ថា JICA ហើយត្រូវបានអនុម័តនៅថ្ងៃទី៥

[4] ហែល ចំរើន, *វិវាទដីធ្លីនៅកម្ពុជា*, រកបាននៅសៀវភៅ វស្សបវត្តិ (បោះពុម្ពផ្សាយដោយការឧបត្ថម្ភពីក្រុមសហប្រតិបត្តិការ សកម្មភាពវប្បធម៌របស់ស្ថានទូតបារាំង ២០០៧),៤៩។

[5] ហែល ចំរើន, *វិវាទដីធ្លីនៅកម្ពុជា*, រកបាននៅសៀវភៅ វស្សបវត្តិ (បោះពុម្ពផ្សាយដោយការឧបត្ថម្ភពីក្រុមសហប្រតិបត្តិការ សកម្មភាពវប្បធម៌របស់ស្ថានទូតបារាំង ២០០៧), ៥១-៥២, ៦៣។

ខែតុលា ឆ្នាំ២០០៧ និង ប្រកាសឲ្យប្រើនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។ ការបែងចែកទ្រព្យត្រូវអនុវត្ត តាមក្រមរដ្ឋប្បវេណី ហើយជាពិសេសក្រមនេះបានចែងយ៉ាងល្អិតល្អន់អំពីបុគ្គលដែលមានសិទ្ធិ ក្លាយជាសន្តតិជនក្រោយពីមតកជនបានទទួលមរណភាព មិនមែនមានតែកូនម្នាក់តែប៉ុណ្ណោះទេ ដែលត្រូវទទួលបានសិទ្ធិជាសន្តតិជន គឺមានន័យថាកូនទាំងអស់ទោះបីជាកូនសុំក្តី កូនបង្កើតក្តីក៏ ត្រូវទទួលមតិកស្មើៗគ្នាទាំងអស់ សូម្បីតែសហព័ទ្ធក៏ត្រូវក្លាយជាសន្តតិជនជានិច្ច[6]ផងដែរ ម្យ៉ាងទៀត ច្បាប់បានចង្អុលបង្ហាញពីនីតិវិធីនៃការបែងចែកទ្រព្យក្នុងរបបសន្តតិកម្ម សន្តតិកម្មតាមច្បាប់ សន្តតិកម្មតាមមតកសាសន៍ ភាគបម្រុង ការយល់ព្រមការបោះបង់សន្តតិកម្ម ការគ្រប់គ្រង និង ការបែង ចែកមតិក ជាដើមចំពោះមតកជនណាដែលមានសន្តតិជនមកបន្តនូវសិទ្ធិ។

លើសពីនេះទៅទៀតប្រសិនបើមតកជននោះពុំមានសន្តតិជនដើម្បីបន្តនូវសិទ្ធិ និង កាតព្វកិច្ច ពីមតកជនទេនោះ ការបែងចែកទ្រព្យអាចធ្វើការបែងចែកទៅឲ្យជនមាននិស្ស័យពិសេស ឬ អាច ក្លាយជានីតិបុគ្គលមតិក ប្រសិនបើនីតិវិធីនៃការស្វែងរកសន្តតិជនមិនអាចរកឃើញសន្តតិជនទេ នោះ បញ្ហានេះក៏មានចែងនៅក្នុងជំពូកទី៧ ស្តីពីនត្ថិភាពនៃសន្តតិជន នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ នេះជាបញ្ហាមួយទោះបីជាវាមិនសូវកើតមានជាញឹកញាប់នៅក្នុងសង្គមក៏ដោយ ក៏ប៉ុន្តែដោយយល់ ឃើញថាពុំទាន់មានការបកស្រាយ ឬ វិធានការសម្រាប់ដោះស្រាយណាមួយនៅឡើយដែលគេតែង តែមើលរំលង ដោយសារការចង់ដឹងអំពីបញ្ហានេះឲ្យកាន់តែច្បាស់ទើបជម្រុញឲ្យមានការសិក្សា ស្រាវជ្រាវ និង បានរៀបចំតាក់តែងអំពី អត្ថិភាព និង នត្ថិភាពនៃសន្តតិជននៅក្នុងរបបសន្តតិកម្មថា តើ អាចកត់សម្គាល់បានថាលក្ខខណ្ឌណាបញ្ជាក់ថាជាអត្ថិភាព លក្ខខណ្ឌណាដែលជានត្ថិភាព? ហើយ ត្រូវមាននីតិវិធីអ្វីខ្លះក្នុងករណីដែលពុំដឹងច្បាស់អំពីសន្តតិជន? ឬ តើការស្វែងរកសន្តតិជនធ្វើឡើង ប៉ុន្មានដំណាក់កាល ហើយបើរកមិនឃើញសន្តតិជនទេតើទ្រព្យរបស់មតកជននឹងត្រូវធ្វើដូចម្តេច? ចម្ងល់ទាំងអស់នេះនឹងត្រូវបានបកស្រាយនៅក្នុងប្រធានបទខាងក្រោមនេះ។

[6] សន្តតិជនជានិច្ច គឺជាសហព័ទ្ធដែលទៅប្រកួតប្រជែងជាមួយសន្តតិជនទាំងបីលំដាប់។

# ជំពូកទី១
# នីតិវិធីស្វែងរកសន្តិជន

## ជំពូកទី១៖ នីតិវិធីស្វែងរកសន្តតិជន

សេរីភាពក្នុងការចាត់ចែងទ្រព្យសម្បត្តិ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងវិស័យច្បាប់ចាប់តាំងពីពេលដែលរូបវន្តបុគ្គលបានចាប់កំណើតរហូតដល់ទទួលមរណភាព ប៉ុន្តែប្រសិនបើបុគ្គលនោះរស់នៅឯកោតែម្នាក់ឯងនៅក្នុងសង្គម តើការបែងចែកទ្រព្យរបស់គាត់អាចប្រព្រឹត្តទៅបានតាមវិធីណាក្រោយពីគាត់ទទួលមរណភាពហើយ? ជាទូទៅ នៅពេលដែលមានមនុស្សម្នាក់ទទួលមរណភាព ទ្រព្យសម្បត្តិរបស់គាត់ត្រូវបន្តដោយសន្តតិជន។ ប៉ុន្តែ ប្រសិនបើគាត់រស់នៅដោយគ្មានសហព័ទ្ធ កូន សាច់ញាតិ ឬ មិនបានដឹងអំពីសាច់ញាតិរបស់គាត់ ព្រោះតែការព្រាត់ប្រាសគ្នានៅក្នុងអំឡុងពេលមានសង្គ្រាម ឬ ជាពិសេសក្រោយពេលមានសង្គ្រាម បានឃ្លាតចាកពីគ្នាដោយមិនដឹងថានៅរស់រានមានជីវិត ឬ បាត់បង់ជីវិតនោះទេ នេះជាស្ថានភាពមួយដែលពិបាកបែងចែកទ្រព្យសម្បត្តិរបស់គាត់ដោយសារតែភាពមិនច្បាស់លាស់ថាតើមានសន្តតិជន ឬ គ្មាន។

ស្ថិតនៅក្នុងករណីដែលមិនដឹងច្បាស់ថាមានសន្តតិជន ជាការចាំបាច់ត្រូវតែមាននីតិវិធីក្នុងការស្វែងរកសន្តតិជនជាមុនសិនមុននឹងឈានដល់ការបែងចែកមត៌ក ម៉្យាងទៀតគឺត្រូវប្រាកដថាមតកជននោះមានសន្តតិជនដែរ ឬ ទេ? ហេតុដូចនេះហើយ មានតែអង្គការតុលាការប៉ុណ្ណោះដែលមានសមត្ថកិច្ចបែងចែកទ្រព្យទាំងនោះទៅតាមច្បាប់។ ប្រសិនបើ តុលាការរកឃើញថាមតកជនមានសន្តតិជនដោយមានគ្រប់លក្ខខណ្ឌតាមបញ្ញត្តិច្បាប់ហើយ នោះការបែងចែកមត៌ក ពុំមានការចោទជាបញ្ហាឡើយ ហើយការបែងចែកនេះគឺធ្វើឡើងតាមរយៈការផ្ទេរទ្រព្យទៅឲ្យសន្តតិជននោះផ្ទុយទៅវិញ ប្រសិនបើរកមិនឃើញសន្តតិជនទេនោះ ទ្រព្យសម្បត្តិដែលនៅសល់ត្រូវប្រគល់ទៅជនមាននិស្ស័យពិសេស ឬ ជនផ្សេងៗទៀតដែលច្បាប់បានកំណត់ ឬ ធ្លាក់ទៅជាទ្រព្យរបស់រដ្ឋ។

មុននឹងមាននីតិវិធីស្វែងរកសន្តតិជនលុះត្រាតែមានមរណភាពនៃមតកជនជាមុនសិន ប្រសិនបើគ្មានភាពច្បាស់លាស់ថាមានសន្តតិជនទេ មត៌កនោះនឹងក្លាយជានីតិបុគ្គលមត៌កដោយស្វ័យប្រវត្តិទោះបីមត៌កមានចំនួនតិចតួច ឬ គ្មាននរណាម្នាក់ដាក់ពាក្យសុំតែងតាំងក៏ដោយ ក៏នីតិបុគ្គលមត៌កនៅតែកើតមានដោយស្វ័យប្រវត្តិដែរ[7]។ ការបង្កើតនីតិបុគ្គលមត៌កមិនតម្រូវឲ្យមាននីតិវិធីឡើយ ប៉ុន្តែប្រសិនបើគ្មានអ្នកគ្រប់គ្រង ក៏គ្មានការចាប់ផ្តើមនីតិវិធីស្វែងរកសន្តតិជនដែរ។

ហេតុដូចនេះ ជំពូកទី១នឹងធ្វើការសិក្សាទៅលើ នីតិវិធីស្វែងរកសន្តតិជន ដែលមានដំណាក់កាលនីមួយៗក្នុងការអនុវត្តនីតិវិធីនេះ។

[7] មាត្រា១២៩០ និង មាត្រា១២៩១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

### ១.១. ដំណាក់កាលទី១៖ ការជ្រើសតាំងអ្នកគ្រប់គ្រង

ទ្រព្យសម្បត្តិរបស់មតកជនត្រូវបានតុលាការជ្រើសតាំងឲ្យបុគ្គលណាមួយមកគ្រប់គ្រងជាបណ្ដោះអាសន្នតាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ដូចជា ម្ចាស់បំណុល អច្ច័យលាភី ជនមាននិស្ស័យពិសេស ឬ មេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានចុងក្រោយរបស់មតកជន ឬ តំណាងអយ្យការ[8]។ តុលាការបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចាត់តាំងបុគ្គលណាមួយមកគ្រប់គ្រង ប៉ុន្តែទាល់តែមានការស្នើសុំពីបុគ្គលខាងលើ។ តុលាការគួរតែជ្រើសរើសអ្នកគ្រប់គ្រងដែលជាបុគ្គលមានសមត្ថភាពនិងសាកសមឲ្យទទួលមុខងារនេះ ដែលអាចជាអ្នកច្បាប់ ឬ មេធាវីជាដើម[9]។

### ១.២. ដំណាក់កាលទី២៖ ការជូនដំណឹងជាសាធារណៈលើកទី១ ដោយតុលាការ

បន្ទាប់ពីតុលាការជ្រើសតាំងអ្នកគ្រប់គ្រងមតិកហើយ តុលាការត្រូវមានតួនាទីក្នុងការជូនដំណឹងជាសាធារណៈអំពីការជ្រើសតាំងអ្នកគ្រប់គ្រងនេះ ដោយគ្មានការយឺតយ៉ាវឡើយ[10]។ ការជូនដំណឹងជាសាធារណៈត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និង ចុះក្នុងព្រឹត្តបត្ររបស់ក្រសួងយុត្តិធម៌[11]។ ការជូនដំណឹងជាសាធារណៈនេះ ត្រូវកំណត់អំឡុងពេលជាក់លាក់ដែលមានរយៈពេល ២ខែ[12]។

### ១.៣. ដំណាក់កាលទី៣៖ ការជូនដំណឹងជាសាធារណៈលើកទី២ ដោយអ្នកគ្រប់គ្រង

ក្រោយពេលកំណត់រយៈ២ខែនៃការជូនដំណឹងជាសាធារណៈអំពីការជ្រើសតាំងអ្នកគ្រប់គ្រងហើយ បើនៅពុំដឹងច្បាស់អំពីសន្តតិជនទេ នោះការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និង ចុះក្នុងព្រឹត្តបត្ររបស់ក្រសួងយុត្តិធម៌[13]។ ការជូនដំណឹងជាសាធារណៈនេះ សម្រាប់ការបង្ហាញអំពីការទាមទាររបស់ម្ចាស់បំណុល និង អច្ច័យលាភី។ ការជូនដំណឹងនេះត្រូវបង្ហាញអំពីចំណុចសំខាន់ៗដូចជា៖

---

[8] មាត្រា១២៩១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[9] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦៖ គន្ថីទី៨-ទី៩*, (ភ្នំពេញ៖ ការិយាល័យកម្មវិធីអភិវឌ្ឍផ្នែកច្បាប់ និង យុត្តិធម៌នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា, ២០១០), ១៥២។

[10] មាត្រា១២៩១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[11] មាត្រា១២ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។

[12] មាត្រា១២៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[13] មាត្រា១២៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និង មាត្រា១២ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។

- ត្រូវបង្ហាញថា គ្រប់សន្តតិជន និង អច្ច័យលាភីទាំងអស់ត្រូវបង្ហាញពីការទាមទាររបស់ពួកគេ នៅក្នុងអំឡុងពេលមិនតិចជាង ២ខែឡើយ ដោយយោងតាមមាត្រា ១២៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី
- ត្រូវសរសេរថា ម្ចាស់បំណុលដែលមិនបានបង្ហាញពីការទាមទាររបស់ពួកគេនៅក្នុងអំឡុងពេលកំណត់ខាងលើនេះទេ ការទាមទារនឹងត្រូវបានដកចេញពីការជម្រះ ដោយយោងតាមមាត្រា១២៩៦ កថាខណ្ឌទី១ និង មាត្រា១២៨១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

## ១.៤. ដំណាក់កាលទី៤៖ ការជូនដំណឹងជាសាធារណៈលើកទី៣ ដោយតុលាការ

ក្នុងដំណាក់កាលនេះ មានការជូនដំណឹងជាសាធារណៈសម្រាប់ការស្វែងរកសន្តតិជន។ បន្ទាប់ពីការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុលបានកន្លងផុតទៅ បើនៅមិនទាន់ដឹងច្បាស់អំពីសន្តតិជនទេ តុលាការត្រូវជូនដំណឹងជាសាធារណៈអំពីការស្វែងរកសន្តតិជនទៅតាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ឲ្យច្បាស់អំពីរយៈពេលកំណត់មួយដែលមិនឲ្យតិចជាង ៦ខែ និង ត្រូវសរសេរថា បើមានសន្តតិជនពួកគេត្រូវធ្វើការស្នើសុំនិងអះអាងថាខ្លួនជាសន្តតិជននៅក្នុងអំឡុងពេលកំណត់នោះ[14]។ គោលបំណងនៃការជូនដំណឹងនេះ គឺដើម្បីផ្តល់ទ្រព្យសម្បត្តិដែលនៅសល់ទៅឲ្យសន្តតិជន។ ប្រសិនបើប៉ាន់ប្រមាណឃើញថា គ្មានសេសសល់មតិកទេ នោះអ្នកគ្រប់គ្រង ឬ តំណាងអយ្យការ មិនអាចធ្វើការទាមទារឲ្យមានការជូនដំណឹងនេះទេ[15]។ ការជូនដំណឹងជាសាធារណៈអំពីការស្វែងរកសន្តតិជននេះ ក៏ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និង ចុះក្នុងព្រឹត្តបត្ររបស់ក្រសួងយុត្តិធម៌[16]។

ប្រសិនបើគ្មានសន្តតិជន ម្ចាស់បំណុល និង អច្ច័យលាភីណាបង្ហាញខ្លួនក្នុងអំឡុងពេលខាងលើនេះទេ សន្តតិជនទាំងអស់នឹងបាត់បង់សិទ្ធិរបស់ខ្លួន ហើយម្ចាស់បំណុល និង អច្ច័យលាភីទាំងអស់ដែលអ្នកគ្រប់គ្រងស្គាល់នឹងបាត់បង់សិទ្ធិដូចគ្នា ពួកគេមិនអាចអនុវត្តសិទ្ធិរបស់ពួកគេបានឡើយ ទោះបីជានៅសល់មតិកក្រោយពីការជម្រះក៏ដោយ។ ប្រសិនបើសន្តតិជនបានបង្ហាញខ្លួនក្រោយការរលត់នៃសិទ្ធិ សន្តតិជននេះមិនមានសិទ្ធិទទួលបាននូវផ្នែកណាមួយនៃមតិកឡើយ[17]។

[14] មាត្រា១២៩៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[15] មាត្រា១២៩៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[16] មាត្រា១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។
[17] មាត្រា១២៩៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ដូចនេះនីតិវិធីនៃការស្វែងរកសន្តតិជន អាចធ្វើឲ្យតុលាការរកឃើញសន្តតិជន ឬ ពុំមានសន្តតិជន នាំឲ្យរបបសន្តតិកម្មបែងចែកជាពីរករណី គឺ អត្ថិភាពនៃសន្តតិជន (ជំពូកទី២) និង នត្ថិភាពនៃសន្តតិជន (ជំពូកទី៣)។

# ជំពូកទី២

# អត្ថិភាព

## ជំពូកទី២៖ អត្តិភាព

ការបញ្ជាក់អំពីអត្តិភាព ត្រូវមានលក្ខខណ្ឌស្របតាមបញ្ញត្តិនៃច្បាប់។ នៅក្នុងអំឡុងពេលប្រកាសជាសាធារណៈ ប្រសិនបើមានបុគ្គលណាមួយបានបង្ហាញខ្លួនជាសន្តតិជន ជននោះត្រូវដាក់ពាក្យស្នើសុំទៅតុលាការដើម្បីបញ្ជាក់ពីអត្តិភាពនៃសន្តតិជន ដើម្បីធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណសន្តតិជនឲ្យបានច្បាស់លាស់ ដោយភ្ជាប់ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណដែលមានទំនាក់ទំនងញាតិជាមួយនឹងមតកជន ដូចជាសំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬឯកសារអត្រានុកូលដ្ឋានផ្សេងទៀត ដែលអាចបញ្ជាក់អំពីទំនាក់ទំនងញាតិ[18]។ ប៉ុន្តែប្រសិនបើឯកសារអត្រានុកូលដ្ឋានមានភាពមិនប្រក្រតីដោយមានការក្លែងបន្លំវិញនោះ តើគួរដោះស្រាយដូចម្ដេច? ដើម្បីការពារករណីបែបនេះកើតឡើង មុននឹងធ្វើការទទួលស្គាល់ជននោះថាជាសន្តតិជនពិតប្រាកដ តុលាការត្រូវត្រួតពិនិត្យលើឯកសារទាំងនោះឲ្យបានច្បាស់លាស់ថា តើឯកសារអត្រានុកូលដ្ឋាននេះត្រឹមត្រូវដែរ ឬ ទេ។ បើមានមន្ទិលសង្ស័យតុលាការគួរតែឲ្យអ្នកជំនាញមកពិនិត្យនិងធ្វើកោសល្យវិច័យលើឯកសារនោះចៀសវាងមានការក្លែងបន្លំធ្វើជាសន្តតិជន ព្រោះក្នុងករណីនេះជាឱកាសល្អរបស់ជនខិលខូចដែលមានបំណងចង់បន្លំឯកសារអត្រានុកូលដ្ឋានធ្វើជាសន្តតិជនក្លែងក្លាយដើម្បីទទួលបានមតិករបស់មតកជន ឬ ការពារកុំឲ្យមានការភ័ន្តច្រឡំលើឯកសារអត្រានុកូលដ្ឋានកើតឡើងដោយការធ្វេសប្រហែសណាមួយ។ ម៉្យាងទៀតតុលាការអាចឲ្យមេឃុំ ឬចៅសង្កាត់ដែលបានចេញឯកសារនោះមកបញ្ជាក់អំពីភាពពិតនៃឯកសារ។ ប្រសិនបើជននោះពិតជាសន្តតិជនប្រាកដមែន នោះជាការបញ្ជាក់អំពីអត្តិភាពនៃសន្តតិជន ដែលត្រូវនឹងមកបន្តនូវសិទ្ធិ និង កាតព្វកិច្ចពីមតកជន។

ហេតុដូចនេះ ជំពូកនេះនឹងធ្វើការសិក្សាទៅលើចំនុចបីសំខាន់ៗ គឺ **លក្ខណៈនៃអត្តិភាព** (២.១) **ការទទួលស្គាល់សន្តតិកម្ម** (២.២) **អត្តិភាពធ្វើឲ្យរលត់សិទ្ធិរបស់អ្នកគ្រប់គ្រង** (២.៣) និង **ការធ្វើបដិទានសន្តតិកម្ម** (២.៤)។

[18] អ៊ីវ ប៉ូលី, *ការបែងចែកមតិក,* (២០១៥), ៧៥, https://www.jica.go.jp/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_03_02.pdf (ចូលទស្សនាថ្ងៃទី ០៥ មេសា ២០១៩)។

## ២.១. លក្ខណៈនៃអត្ថិភាព

អត្ថិភាព សំដៅលើភាវៈមាន ភាពនៃអ្វីៗដែលមាន ការមាន[19]។ មួយវិញទៀត អត្ថិភាព សំដៅលើ ភាពមាន ឬ ភាវៈដែលមាន[20]។ លក្ខណៈនៃអត្ថិភាពនេះ គឺជាការបង្ហាញថាមានសន្តតិជន។ ការបញ្ជាក់អំពីអត្ថិភាពនៃសន្តតិជន គឺតម្រូវឲ្យមានលក្ខខណ្ឌចាំបាច់មួយចំនួនដូចខាងក្រោម៖

- លក្ខណៈសម្បត្តិជាសន្តតិជន
- បុគ្គលដែលមានសិទ្ធិជាសន្តតិជន

### ២.១.១. លក្ខណៈសម្បត្តិជាសន្តតិជន

បន្ទាប់ពីធ្វើការស្នើសុំនិងអះអាងថាបុគ្គលនោះជាសន្តតិជន គឺតម្រូវឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជនដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ទើបអាចប្រគល់មតិកទៅឲ្យគាត់កាន់កាប់បន្តបាន។ លក្ខណៈទាំងអស់នោះដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីមានដូចជា សន្តតិជនត្រូវតែមានជីវិតរស់នៅ និង មិនមែនជាបុគ្គលដែលផ្ដោះសិទ្ធិជាសន្តតិជន។

#### ២.១.១.១. បុគ្គលដែលមានជីវិតរស់នៅ

ជាធម្មតារូបវន្តបុគ្គលម្នាក់ៗចាប់ផ្ដើមទទួលបានសិទ្ធិនៅពេលចាប់កំណើតហើយត្រូវបានបញ្ចប់ទៅវិញនៅពេលមរណភាព។ នៅក្នុងរបបសន្តតិកម្មមានតែជនដែលមានជីវិតរស់នៅនាពេលចាប់ផ្ដើមសន្តតិកម្មទេ ទើបអាចទទួលមតិកនោះបាន[21] ប៉ុន្តែក្នុងករណីមួយផ្សេងទៀតដែលសន្តតិជនជាជនបាត់ខ្លួន នៅពេលដែលគាត់ត្រលប់មកវិញគាត់អាចទាមទារសិទ្ធិដើម្បីក្លាយជាសន្តតិជនវិញបាន។

យោងតាមមាត្រា៤៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថា ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ មានការបញ្ជាក់ថាទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួនតាមពាក្យស្នើសុំរបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍។ បុគ្គលដែលទទួលបានទ្រព្យសម្បត្តិដោយចំពោះ ដោយសារតែអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ត្រូវបាត់បង់សិទ្ធិព្រោះការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ។ មានន័យថា ប្រសិនបើបុគ្គលដែលបាត់ខ្លួនដោយពុំដឹងច្បាស់លាស់ថានៅរស់ ឬ ទទួលមរណភាពដែលតុលាការបានប្រកាសអំពីការបាត់ខ្លួនតាមពាក្យស្នើសុំរបស់ជនមានផលប្រយោជន៍ ស្រាប់តែជននោះត្រលប់មក

---

[19] វចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត។

[20] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ*, (ភ្នំពេញ៖ ជោគជ័យ, ឆ្នាំ២០១៧),៤៥០។

[21] មាត្រា១១៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

វិញ គាត់ត្រូវទទួលបានសិទ្ធិដោយទទួលបានមតិកនៅក្នុងរបបសន្តតិកម្មនេះ ហើយបុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួនមានកាតព្វកិច្ចសងត្រលប់មកជនបាត់ខ្លួនវិញ។

**២.១.១.២. បុគ្គលដែលមិនថ្លោះសិទ្ធិជាសន្តតិជន**

កត្តាមួយចំនួនទៀតដែលបង្ហាញថា បុគ្គលទាំងនោះមិនថ្លោះសិទ្ធិជាសន្តតិជន គឺជាជនដែលមិនមែនជាអភ័ព្វបុគ្គល និង មិនត្រូវបានផ្តាច់មតិកពីសន្តតិកម្មនោះ។

**ក. ជនមិនមែនជាអភ័ព្វបុគ្គល**

ករណីមួយចំនួនដែលបានសន្មតថាបុគ្គលនោះមិនមែនជាអភ័ព្វបុគ្គលនៃសន្តតិកម្មគឺករណីដែលផ្ទុយពីអត្ថន័យនៃមាត្រា១១៥០នៃក្រមរដ្ឋប្បវេណី មានដូចជា៖

**ក**.បុគ្គលដែលមិនបានប្រព្រឹត្តបទល្មើសមានដូចជា ចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នាទោះដោយផ្ទាល់ក្តី ដោយប្រយោលក្តី។ មានន័យថា បុគ្គលនោះមិនបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋទៅលើមតកជន ឬ សន្តតិជនដទៃទៀតក្នុងគោលបំណងទុច្ចរិតដើម្បីដណ្តើមយកមតិកមកធ្វើជាទ្រព្យផ្តាច់មុខរបស់ខ្លួនដោយគ្មានបំណងចែករំលែកទៅឲ្យសន្តតិជនដទៃទៀត។

**ខ**.បុគ្គលដែលមិនមែនជាជនដែលបានដឹងអំពីការសម្លាប់មតកជន គឺបុគ្គលនោះមិនបានដឹងថាសន្តតិជនណាម្នាក់បានធ្វើឃាតលើមតកជនទេ។

**គ**.បុគ្គលដែលមិនមែនជាជនដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬ គំរាមគំហែង។ សំដៅលើជនដែលចៀសផុតពីអំពើរារាំងមតកជនក្នុងការធ្វើមតកសាសន៍ ដោយលុបចោល ឬ កែប្រែ ឬ គំរាមគំហែង ដើម្បីទទួលបានមតិកច្រើនជាងសន្តតិជនដទៃ។

**ឃ**.បុគ្គលដែលមិនមែនជាជនដែលបានឲ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គំរាមគំហែង។ ជាជនដែលមិនបានបង្ខំ ឬ ធ្វើសកម្មភាពណាមួយដែលឲ្យមតកជនកែប្រែមតកសាសន៍នោះទេ។

**ង**. បុគ្គលដែលមិនមែនជាជនដែលបាន ក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន។ សំដៅលើជនដែលមិនបានប្រព្រឹត្តនូវអំពើនានាក្នុងគោលបំណងទុច្ចរិតចំពោះមតកសាសន៍ ដូចជា ក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកលិខិតមតកសាសន៍ ដោយសារតែខ្លួនទទួលបានមតិកតិចជាងសន្តតិជនដទៃ។

**ខ. បុគ្គលដែលមិនបានផ្តាច់មត៌កចេញពីសន្តតិកម្ម**

កាលដែលមតកជនពេលនៅរស់មិនបានផ្តាច់មត៌កពីសន្តតិជនតាមសាលក្រមរបស់តុលាការ ដោយយោងតាមមាត្រា១១៥១ នៃក្រមរដ្ឋប្បវេណី ឬ ការផ្តាច់មត៌កពីសន្តតិជនដោយមតកសាសន៍ ដោយយោងតាមមាត្រា១១៥២ នៃក្រមរដ្ឋប្បវេណី នោះសន្តតិជនមិនបានទទួលអានុភាពថ្លោះសិទ្ធិជាសន្តតិជនឡើយ។ បានន័យថា ក្នុងអំឡុងពេលដែលមតកជននៅរស់ គាត់មិនមានឆន្ទៈក្នុងការកាត់ផ្តាច់មត៌កចេញពីសន្តតិកម្មរបស់ជនណាឡើយ នោះនាំឲ្យជនដែលមិនត្រូវបានផ្តាច់ចេញនេះ នៅមានសិទ្ធិជាសន្តតិជននៅពេលក្រោយមតកជនបានទទួលមរណភាព។ ដោយហេតុនេះ សន្តតិជនមានសិទ្ធិបន្តនូវសិទ្ធិ និង ករណីយកិច្ចពីមតកជនដដែល។

**២.១.២. បុគ្គលមានសិទ្ធិជាសន្តតិជន**

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងអំពីការទទួលបានសិទ្ធិជាសន្តតិជន។ លក្ខខណ្ឌមួយចំនួនដែលបានកំណត់ថា បុគ្គលណាខ្លះជាសន្តតិជន គឺត្រូវមានលក្ខខណ្ឌដូចជា សន្តតិជនតាមច្បាប់ សន្តតិជនជំនួស និង សន្តតិជនជាសហាព័ទ្ធ ។

**២.១.២.១. សន្តតិជនតាមច្បាប់**

សន្តតិជនតាមច្បាប់ គេកំណត់ជាសន្តតិជនដែលមានសិទ្ធិនិងកាតព្វកិច្ចដែលមានលំដាប់ថ្នាក់នៃអាទិភាពរបស់ខ្លួនម្នាក់ៗ ទៅតាមថ្នាក់ញាតិលោហិតខ្សែផ្ទាល់ក្នុង៦ថ្នាក់ និង សាខាញាតិ[22]។

រូបវន្តបុគ្គលម្នាក់ៗដែលគ្រប់លក្ខណៈសម្បត្តិតាមច្បាប់កំណត់ ហើយមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម គឺមានសិទ្ធិ និង កាតព្វកិច្ចជាសន្តតិជនបាន។ សន្តតិជនតាមច្បាប់ គឺសំដៅលើសន្តតិជនដែលមានលំដាប់ទាំងបី។

- **សន្តតិជនលំដាប់ទីមួយ៖** គឺជាកូនរបស់មតកជន ទោះបីកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកស្មើៗគ្នា[23]។ ចំពោះកូនបង្កើត ទោះបីជាកូនដែលកើតពីឪពុកម្តាយមានសំបុត្រអាពាហ៍ពិពាហ៍ និង កូនដែលកើតចេញចំណងអាពាហ៍ពិពាហ៍អនីតិសង្វាសក៏ដោយក៏មានការបែងចែកដូចគ្នាទៅនឹងកូនដែលកើតចេញពីឪពុកម្តាយដែលមានសំបុត្រអាពាហ៍ពិពាហ៍ ជាធម្មតាអាពាហ៍ពិពាហ៍អនីតិសង្វាសពុំមានចំណងគតិយុត្តទេ ប៉ុន្តែច្បាប់បានផ្តល់សិទ្ធិឲ្យកូននោះត្រូវទទួលបានមត៌កដូចគ្នាដែរ ប្រសិនបើកូននោះទទួលស្គាល់ដោយឪពុកតាមរយៈការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន ឬ តាមមតកសាសន៍

[22] មាត្រា៩៣៨ និង មាត្រា៩៣៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[23] មាត្រា១១៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ក៏បានដែរ[24]។ ប៉ុន្តែករណីមួយទៀត យោងតាមមាត្រា៩៩៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧បានចែងថា *"បើបុគ្គលណាម្នាក់បានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬ ផ្តិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវចាត់ទុកថា បានទទួលស្គាល់កូននោះនៅពេលដែលបានសុំចុះកំណើត"* គឺបានអនុញ្ញាតឲ្យកូនកើតចេញពីចំណងអនីតិសង្វាសត្រូវបានទទួលស្គាល់ដោយឪពុកអនីតិសង្វាសតាមរយៈការចុះសំបុត្រកំណើតរបស់កូន ដោយចុះឈ្មោះឪពុកនោះ ហើយករណីនេះតែងតែកើតឡើងជាញឹកញាប់នៅក្នុងសង្គមជាក់ស្តែង។ ផ្ទុយទៅវិញ បើឪពុកមិនទទួលស្គាល់កូនអនីតិសង្វាសទេ កូននោះត្រូវទទួលបានមតិកពីម្តាយតែម្នាក់ប៉ុណ្ណោះ ដោយយោងតាមមាត្រា ៩៨៧ ស្ត្រីដែលបានសម្រាលកូនគឺជាម្តាយរបស់កូន។

ចំពោះកូនសុំក៏អាចក្លាយជាសន្តតិជនបានដែរ ព្រោះយោងតាមមាត្រា១១៥៦ កូនគឺជាសន្តតិជនលំដាប់ទីមួយ ទោះបីកូនរបស់មតកជននោះជាកូនបង្កើតក្តី ឬ កូនសុំក្តីក៏បានចំណែកស្មើៗគ្នា។ ហេតុនេះហើយ ទោះបីកូនសុំមិនបានជាប់សាច់ឈាមមតកជនក៏ដោយ ក៏កូនសុំមានសិទ្ធិ និង កាតព្វកិច្ចដូចកូនដែលជាប់លោហិតផងដែរ។ ទោះបីកូនសុំនោះជាកូនសុំដោយការសុំកូនធម្មតា ឬ ការសុំកូនពេញលេញក៏ដោយ កូនសុំនោះនៅតែជាបុគ្គលដែលមានសិទ្ធិធ្វើជាសន្តតិជនបាន ហើយមានសិទ្ធិ និង បំពេញកាតព្វកិច្ចដូចសន្តតិជនដែលមានលំដាប់ទីមួយទៀតផង។

រីឯទារកក្នុងគភ៌វិញ ច្បាប់ក៏បានយកចិត្តទុកដាក់ និង ការពារចំពោះទារកដែលមិនទាន់កើតមកផងដែរ ព្រោះទារកអាចនឹងកើតរស់រានមានជីវិត។ ដោយផ្អែកតាមមាត្រា៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ករណីចំពោះទារកក្នុងគភ៌ នៅពេលចាប់ផ្តើមសន្តតិកម្ម ទារកនេះមានកំណើតអាចកើតមករស់រានមានជីវិត គឺទារកនោះអាចនឹងទទួលបានទ្រព្យដោយសន្តតិកម្មនោះបាន។

- **សន្តតិជនលំដាប់ទីពីរ៖** គឺជាបុព្វញាតិផ្ទាល់របស់មតកជនត្រូវក្លាយជាសន្តតិជន ប្រសិនបើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ[25]។ ប្រសិនបើមតកជនពុំមានសន្តតិជនលំដាប់ទី១ទេ ការបែងចែកមតិកត្រូវផ្ទេរទៅឲ្យបុគ្គលដូចជាឪពុក ម្តាយ ឬ ជីដូន ជីតា របស់មតកជនដែលត្រូវជាសន្តតិជនលំដាប់ទី២។

[24] មាត្រា៩៩៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[25] មាត្រា១១៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

- **សន្តតិជនលំដាប់ទីបី៖** គឺសំដៅលើបងប្អូនបង្កើតរបស់មតកជន។ បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះក្លាយជាសន្តតិជន[26]។

**២.១.២.២. សន្តតិជនជំនួស**

ដោយឡែកនៅមានករណីផ្សេងដែលអាចកើតមានឡើង ក្រោយពីបានរកឃើញសន្តតិជនត្រឹមត្រូវតាមច្បាប់កំណត់ដូចខាងលើរួចហើយ បើសន្តតិជននោះស្រាប់តែទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម កូនរបស់បុគ្គលនោះក្លាយជាសន្តតិជនជំនួស[27]។ បានន័យថា បុគ្គលដែលអាចមានសិទ្ធិក្លាយជាសន្តតិជនស្របច្បាប់រួចហើយ ប៉ុន្តែបែរជាបាត់បង់ជីវិតដោយសារប្រការណាមួយដែលបានកើតឡើង ប្រសិនបើបុគ្គលបាត់បង់ជីវិតនេះមានកូនដែលមានជីវិតរស់នៅ កូននេះនឹងត្រូវបន្តជាសន្តតិជនជំនួសបុគ្គលនោះ ហើយមានសិទ្ធិនិងកាតព្វកិច្ចពេញទីដូចសន្តតិជនដែលទទួលមរណភាពនោះដែរ។ ករណីមួយវិញទៀត បើបុគ្គលនោះរកឃើញហើយ តែមិនមានសិទ្ធិជាសន្តតិជនព្រោះបុគ្គលនោះបានផ្តោះសិទ្ធិហើយក្លាយជាអភ័ព្វបុគ្គល ឬ ដោយសារការផ្តាច់មតិក នាំឲ្យកូនរបស់ជននោះនឹងក្លាយទៅជាសន្តតិជនជំនួស[28]។ មានន័យថា ទោះបីសន្តតិជនដែលបាត់បង់សិទ្ធិនិងកាតព្វកិច្ចដោយសារផ្តោះសិទ្ធិក៏ដោយ ច្បាប់នៅអនុញ្ញាតឲ្យកូនរបស់ជនផ្តោះសិទ្ធិនោះមានសិទ្ធិបន្តក្លាយជាសន្តតិជនជំនួសផងដែរ។ ហេតុនេះមតិកត្រូវតែមានអ្នកមកទទួលជំនួសបុគ្គលដែលជាសន្តតិជនដែលបានទទួលមរណភាព ឬ បុគ្គលដែលផ្តោះសិទ្ធិជាសន្តតិជន។

**២.១.២.៣. សន្តតិជនជាសហព័ទ្ធ**

ដោយយោងតាមមាត្រា១១៦១នៃក្រមរដ្ឋប្បវេណី សហព័ទ្ធរបស់មតកជនគឺត្រូវតែក្លាយជាសន្តតិជនជានិច្ច ទោះបីជាមាន ឬ គ្មានសន្តតិជនផ្សេងទៀតក៏ដោយ។ មានន័យថា ច្បាប់ក៏បានអនុញ្ញាតឲ្យសហព័ទ្ធក្លាយជាសន្តតិជន ហើយត្រូវទទួលបានចំណែកមតិករបស់មតកជន។ សហព័ទ្ធទទួលបានសិទ្ធិជាសន្តតិជនដោយសារចំណងអាពាហ៍ពិពាហ៍បង្កើតបានជាទំនាក់ទំនងគតិយុត្តជាមួយគ្នា ជានិច្ចកាលសហព័ទ្ធដែលក្លាយជាសន្តតិជនត្រូវមានលំដាប់ស្មើគ្នាជាមួយសន្តតិជនដែលជាញាតិលោហិតនោះ ដោយមិនគិតថាជាបច្ឆាញាតិផ្ទាល់ ឬ បុព្វញាតិផ្ទាល់ ឬ បងប្អូនបង្កើតរបស់មតកជនឡើយ។

[26] មាត្រា១១៦០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[27] មាត្រា១១៥៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[28] មាត្រា១១៥៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ចំពោះសហាព័ទ្ធដែលបានបាត់ខ្លួននៅមុនពេលមានសន្តតិកម្មដោយពុំមានអ្នកណាម្នាក់ដឹងថាជននោះស្លាប់ ឬ កំពុងរស់នៅទីណា ជនដែលមានប្រយោជន៍ពាក់ព័ន្ធជាមួយជនដែលបាត់ខ្លួនអាចធ្វើពាក្យបណ្តឹងទៅតុលាការខាងលំនៅដ្ឋានរបស់ជនបាត់ខ្លួននោះដើម្បីធ្វើការសន្មតពីការប្រកាសអំពីការបាត់ខ្លួន ហើយសាលក្រមដែលប្រកាសពីការបាត់ខ្លួនត្រូវបានគេចាត់ទុកថាជាសំបុត្រមរណភាព។ បើជនបាត់ខ្លួននេះត្រលប់មកវិញ ជននេះ ឬ ជនដែលមានប្រយោជន៍ពាក់ព័ន្ធអាចសុំប្តឹងទៅតុលាការសុំមោឃភាពសាលក្រមអំពីការប្រកាសបាត់ខ្លួននោះ។ ដូចនេះទ្រព្យសម្បត្តិរបស់មតកជនត្រូវផ្ទេរទៅឲ្យសហាព័ទ្ធដែលបានរកឃើញវិញទៅតាមសមត្ថភាពដែលទ្រព្យគង់នៅ ប៉ុន្តែបើទ្រព្យនោះបានបែងចែងទៅអោយតតិយជនរួចរាល់ហើយមិនអាចប្រគល់ទៅអោយជននេះវិញបានទេព្រោះជាគោលការណ៍ជននេះគ្មានសិទ្ធិបន្តទេ។ ច្បាប់ខ្មែរពុំបានចែងច្បាស់លាស់អំពីអវត្តមាននោះទេ មានតែច្បាប់បារាំងឃើញមានចែងពីការអវត្តមាន ហើយអាចនិយាយបានថា អវត្តមានគឺជាសកម្មភាពដែលរូបវន្តបុគ្គលបានបាត់ខ្លួនពីលំនៅដ្ឋានរបស់ខ្លួនដោយពុំដឹងស្លាប់ ឬ រស់នៅទីណាដោយគ្មានដំណឹងអស់រយៈពេលជាយូរ ចំណែកឯការបាត់ខ្លួនវិញគឺមិនខុសអំពីអវត្តមានប៉ុន្មានទេគ្រាន់តែការបាត់ខ្លួនគឺសន្មតថាជននោះបានបាត់បង់ជីវិតដោយសារព្រឹត្តការណ៍ណាមួយ[29]។

## ២.២. ការទទួលស្គាល់សន្តតិកម្ម

ក្រោយពីរកឃើញបុគ្គលដែលមានសិទ្ធិក្លាយជាសន្តតិជនរួចមក បុគ្គលនោះនៅមិនទាន់ក្លាយជាសន្តតិជនភ្លាមនោះទេ ដរាបណាគេយល់ព្រមទទួលស្គាល់នូវសន្តតិកម្មនោះ បានន័យថាបុគ្គលនោះមានសិទ្ធិសម្រេចនូវការទទួលស្គាល់ ឬ មិនព្រមទទួលស្គាល់។ ច្បាប់បានផ្តល់សិទ្ធិនេះឲ្យក៏ព្រោះតែមានករណីខ្លះមតកជនបន្សល់បំណុលច្រើនជាងទ្រព្យសកម្ម មានន័យថាទ្រព្យអកម្មច្រើនជាងទ្រព្យសកម្ម ហេតុនេះហើយច្បាប់បានអនុញ្ញាតឲ្យបុគ្គលនោះពិចារណានូវការទទួលស្គាល់ដោយឆន្ទៈរបស់ខ្លួន។ ប្រសិនបើបុគ្គលនេះព្រមទទួលស្គាល់សន្តតិកម្មនេះហើយ សន្តតិជនត្រូវធ្វើការទទួលស្គាល់នៅក្នុងអំឡុងពេល៣ខែ គិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ប៉ុន្តែអំឡុងពេលនេះអាចពន្យាទៀតបានតាមពាក្យសុំរបស់សន្តតិជនទៅតុលាការហើយសន្តតិជនអាចស្រាវជ្រាវមតិកបាននៅមុនពេលធ្វើការយល់ព្រម[30]។ ការទទួលស្គាល់នេះច្បាប់បានបែងចែកជាពីរករណី គឺ ការយល់ព្រមទាំងស្រុង និង ការយល់ព្រមដោយកម្រិត។

[29] អម សុផាណារ៉ាត, "*នីតិរដ្ឋប្បវេណី,*" (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំសិក្សា២០១៥-២០១៦), ទំព័រ៥។

[30] មាត្រា១២៤៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

### ២.២.១. ការយល់ព្រមទាំងស្រុង

ក្រោយពីបានពិចារណាសម្រេចព្រមទទួលស្គាល់សន្តតិកម្មនេះតាមរយៈការយល់ព្រមទាំងស្រុងក្នុងអំឡុងពេលកំណត់នេះហើយ នោះសន្តតិជនត្រូវទទួលបានសិទ្ធិនិងកាតព្វកិច្ចទាំងស្រុងពីមតកជន។ ប៉ុន្តែ បើសន្តតិជនមិនបានធ្វើការយល់ព្រមដោយកម្រិត ឬ បោះបង់ការទទួលស្គាល់ ក្នុងអំឡុងពេលកំណត់បីខែនេះទេ នោះគេចាត់ទុកថាសន្តតិជនធ្វើការយល់ព្រមទាំងស្រុងតាមច្បាប់តែម្តង[31]។ ឬក៏ម្យ៉ាងទៀត បើសន្តតិជនបានចាត់ចែងមតិកនោះទាំងអស់ ឬ មួយភាគ គឺចាត់ទុកថាការយល់ព្រមទាំងស្រុងតាមច្បាប់ដែរ[32]។ ផ្ទុយទៅវិញ បើសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ក៏ដោយ តែបុគ្គលនេះបានលាក់ទ្រព្យទាំងអស់ ឬ មួយភាគ ឬ ប្រើទ្រព្យនោះជារបស់ខ្លួន ច្បាប់បានចាត់ទុកថាជាការយល់ព្រមទាំងស្រុងតាមច្បាប់ផងដែរ។

ក្រោយពីធ្វើការយល់ព្រមទាំងស្រុង ឬ សកម្មភាពដែលបានចាត់ទុកថាបង្កើតអានុភាពនៃការយល់ព្រមទាំងស្រុងរួចហើយ បុគ្គលនោះក្លាយជាសន្តតិជនស្របតាមច្បាប់ ព្រមទាំងទទួលបានសិទ្ធិនិងកាតព្វកិច្ចពីមតកជន ដោយធ្វើការសងបំណុលប្រសិនបើមាន ទោះបីបំណុលនោះមានទំហំច្រើនប៉ុណ្ណាក៏ដោយ។ សន្តតិជនអាចយកទ្រព្យសម្បត្តិដែលជាមតិកនោះមកដោះស្រាយបំណុល ប៉ុន្តែក្នុងករណីដែលបំណុលលើសមតិកទៀត នោះសន្តតិជនត្រូវដោះស្រាយបំណុលដោយវិធីខ្លួនឯង។

### ២.២.២. ការយល់ព្រមដោយកម្រិត

ក្នុងករណីមួយទៀតដែលសន្តតិជនអាចជ្រើសរើសបានគឺ ការយល់ព្រមដោយកម្រិត។ ការយល់ព្រមដោយមានកម្រិតនេះ សន្តតិជនអាចយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ[33]។ បានន័យថាសន្តតិជនព្រមទទួលស្គាល់របបសន្តតិមកម្មនេះ និង ទទួលបានសិទ្ធិ និងកាតព្វកិច្ចបន្តពីមតកជន ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវសងនូវចំនួនបំណុលដែលត្រូវសងត្រឹមតែទ្រព្យដែលគេទទួលបានតែប៉ុណ្ណោះ។ នេះជាវិធីល្អមួយដើម្បីកុំឲ្យសន្តតិជនមានការទទួលខុសត្រូវសងបំណុលដែលមានចំនួនច្រើន ដែលធ្វើឲ្យសន្តតិជនមានការលំបាកក្នុងការប្រឈមនឹងការដោះស្រាយបញ្ហានេះ។

---

[31] មាត្រា១២៥៥ ចំណុចខ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[32] មាត្រា១២៥៥ ចំណុចក នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[33] មាត្រា១២៥៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ដើម្បីឲ្យការយល់ព្រមដោយមានកម្រិតនេះមានអានុភាព សន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការដែលបានកំណត់រយៈពេលដូចបានថែងខាងលើ ព្រមជាមួយនឹងបញ្ជីសារពើភ័ណ្ឌផ្សេងៗដែលទាក់ទងនឹងមតកជន។ សន្តតិជនត្រូវតែធ្វើបញ្ជីសារពើភ័ណ្ឌនេះ ដោយសរសេរពីទ្រព្យសកម្ម និង ទ្រព្យអកម្មឲ្យបានត្រឹមត្រូវ[34]។

## ២.៣. អត្ថិភាពធ្វើឲ្យរលត់សិទ្ធិរបស់អ្នកគ្រប់គ្រង

សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងត្រូវបានរលត់ នៅពេលណាមួយដែលមានសន្តតិជនមកបង្ហាញខ្លួនព្រមទាំងបានទទួលស្គាល់នូវសន្តតិកម្មផងដែរ[35]។ បើមានករណីបែបនេះ អ្នកគ្រប់គ្រងត្រូវប្រគល់នូវសិទ្ធិអំណាចនៃការគ្រប់គ្រងសន្តតិកម្មនេះទៅឲ្យសន្តតិជន ទោះបីសកម្មភាពមួយចំនួនដែលអ្នកគ្រប់គ្រងបានធ្វើដើម្បីថែរក្សានិងគ្រប់គ្រងមតិក ដូចជា ការរាយការណ៍អំពីការទាមទាររបស់ម្ចាស់បំណុល ឬ អច្ច័យលាភី និង ការធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងនឹងមតិកផ្សេងៗហើយក្តីក៏ចាត់ទុកថាមានអានុភាពដែរ ព្រោះដើម្បីផលប្រយោជន៍របស់តតិយជន បន្ថែមពីនេះទៀត អ្នកគ្រប់គ្រងត្រូវបង្ហាញនូវការគ្រប់គ្រងរបស់ខ្លួនទៅឲ្យសន្តិជនឲ្យបានច្បាស់លាស់ផងដែរ។

## ២.៤. ការធ្វើបដិទានសន្តតិកម្ម

ការធ្វើបដិទានសន្តតិកម្ម ក៏ជាផ្នែកមួយនៃអត្ថិភាពនៃសន្តតិជនបានដែរ ព្រោះករណីខ្លះប្រសិនបើមតកជនមានកូនដែលជាសន្តតិជនលំដាប់ទី១ ហើយគ្មានអ្នកណាម្នាក់បានដឹងច្បាស់ពីព័ត៌មានកូនរបស់គាត់ដោយសារតែការបែកបាក់ណាមួយបណ្តាលឲ្យគាត់ត្រូវឃ្លាតឆ្ងាយទៅរស់នៅឯបរទេសអស់រយៈពេលជាយូរ។ ក្រោយពីមរណភាពរបស់មតកជន ប្រសិនបើសន្តតិជនលំដាប់ទី៣ ដែលត្រូវជាបងប្អូនបង្កើតរបស់មតកជនមានបំណងទុច្ចរិតលោភលន់ចង់បានមតិករបស់មតកជនដោយការធ្វើបណ្តឹងទៅតុលាការថាមតកជនពុំមានសន្តតិជនទេ ហើយអះអាងថាខ្លួនជាសន្តតិជនតែមួយគត់របស់មតកជនដើម្បីទាមទារទ្រព្យសម្បត្តិរបស់មតកជនមកធ្វើជារបស់ខ្លួន នាំឲ្យតុលាការមិនអាចដឹងបានឡើយថាមតកជនពិតជាពុំមានសន្តតិជនលំដាប់មួយពិតប្រាកដមែនហើយឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណក៏មិនអាចបញ្ជាក់ពីភាពមិនប្រក្រតីណាមួយដែរ ព្រោះឯកសារអត្រានុកូលដ្ឋានទាំងអស់ត្រឹមត្រូវតាមច្បាប់ដែលអាចបញ្ជាក់ថាសន្តតិជនលំដាប់ទី៣ពិតជាមានទំនាក់ទំនងញាតិជាបងប្អូនជាមួយនឹងមតកជនពិតប្រាកដមែន។

ក្នុងករណីនេះបើតុលាការយល់ព្រមតាមការទាមទាររបស់សន្តតិជនលំដាប់ទី៣ដែលបានផ្តល់ព័ត៌មានមិនពិតទៅតុលាការ ដោយសន្តតិជនលំដាប់ទី១មិនបានដឹងដំណឹងមរណភាពរបស់មតកជន

[34] មាត្រា១២៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[35] មាត្រា១២៩៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

លុះក្រោយមកបើសន្តតិជនលំដាប់ទី១បានដឹងដំណឹងមរណភាពនេះ ហើយបានប្ដឹងទៅតុលាការក្នុងអំឡុងពេល៥ឆ្នាំបន្ទាប់ពីពេលមតកជនទទួលមរណភាពដើម្បីទាមទារឲ្យធ្វើបដិទានសន្តតិកម្មនៃចំណែកមតិករបស់ខ្លួន[36]។ សន្តតិជនលំដាប់ទី១អាចសុំឲ្យតុលាការធ្វើបដិទានសន្តតិកម្មនោះត្រឡប់មកវិញ ដើម្បីទទួលបានមតិកទាំងអស់ ឬ មួយភាគមកវិញបាន[37] ព្រោះយោងតាមមាត្រា១៣០២ នៃក្រមរដ្ឋប្បវេណីបានចែងថា សន្តតិជនអាចទាមទារចំពោះជនដែលបានទទួលមតិកតាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឲ្យប្រគល់មកវិញនូវទ្រព្យដែលទទួលបាននោះ។ មានន័យថាសន្តតិជនលំដាប់ទី១អាចប្ដឹងទៅតុលាការដើម្បីទាមទារមតិកដែលត្រូវជាទ្រព្យសម្បត្តិរបស់ខ្លួនមកវិញបាន ហើយសន្តតិជនលំដាប់ទី៣ត្រូវមានកាតព្វកិច្ចប្រគល់ទ្រព្យសម្បត្តិដែលខ្លួនបានកាប់កាន់នូវមតិករបស់មតកជនដោយទុច្ចរិត ត្រូវប្រគល់ទ្រព្យសម្បត្តិទាំងអស់ទៅឲ្យសន្តតិជនលំដាប់ទី១ដែលជាកូនវិញ រួមទាំងការប្រាក់ដែលបានទទួលពីការកាន់កាប់មតិក ហើយគ្មានសិទ្ធិទាមទារ ឬ ទទួលបានសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលខ្លួនបានសងនោះទេ ថែមទាំងគ្មានសិទ្ធិក្នុងការទាមទារឲ្យសងមកវិញនូវសោហ៊ុយដែលបានបង្កើនចំពោះទ្រព្យនោះផងដែរ តាមរយៈការទាមទារឲ្យធ្វើបដិទានសន្តតិកម្មរបស់សន្តតិជនលំដាប់១នេះ[38]។

[36] មាត្រា១៣០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[37] មាត្រា១៣០១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[38] មាត្រា១៣០៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

# ជំពូកទី៣

# នត្តិភាព

## ជំពូកទី៣៖ នត្ថិភាព

ការស្វែងរកសន្តតិជនស្របតាមនីតិវិធីច្បាប់ ដែលត្រូវទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ច គឺជាលក្ខខណ្ឌចាំបាច់ក្នុងរបបសន្តតិកម្ម។ ប្រសិនបើការស្វែងរកនោះពុំមានសន្តតិជន ឬ មានភាពមិនច្បាស់លាស់ថាមានសន្តតិជន ដូចជា ច្បាស់ថាមិនមានសន្តតិជនដោយជននោះបានបាត់បង់ជីវិត (យោងតាមមាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា មានតែជនដែលមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម ទើបអាចទទួលសន្តតិកម្មបាន) ក្នុងករណីដែលជននោះបានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្មហើយគ្មានសន្តតិជនជំនួស តាមច្បាប់បានចែងថានត្ថិភាពនៃសន្តតិជននៅក្នុងជំពូកទី៧ (នត្ថិភាពនៃសន្តតិជន)។ ម៉្យាងទៀត មានសន្តតិជនដែរ តែពួកគេគឺជាអភ័ព្វបុគ្គល (មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណី) ឬ ជាជនដែលត្រូវបានផ្តាច់មត៌ក (មាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី) ឬ មានសន្តតិជនដែរ ប៉ុន្តែពួកគេទាំងអស់បោះបង់សន្តតិកម្ម (មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណី) ក៏នាំឲ្យនត្ថិភាពនៃសន្តតិជនដែរ។ លក្ខណៈអ្វីខ្លះដែលបញ្ជាក់ថានត្ថិភាពនៃសន្តតិជន? ប្រសិនបើពុំអាចស្វែងរកសន្តតិជនបានក្នុងអំឡុងពេលដំណើរការនីតិវិធីនេះទេ ថាតើការបែងចែកមត៌កនេះត្រូវអនុវត្តតាមរបៀបណា?

ហេតុដូចនេះ ជំពូកនេះនឹងធ្វើការសិក្សាទៅលើចំណុចបីសំខាន់ៗ គឺ **លក្ខណៈនៃនត្ថិភាព** (៣.១) **ការបោះបង់សន្តតិកម្ម** (៣.២) **ការចាត់ចែងមត៌ក** (៣.៣) និង **ករណីនត្ថិភាពនៃសន្តតិជននៅសហរដ្ឋអាមេរិក** (៣.៤)។

### ៣.១. លក្ខណៈនៃនត្ថិភាព

នត្ថិភាព គឺភាវៈគ្មាន ភាពនៃអ្វីៗដែលមិនមាន ការឥតមាន[39]។ មួយវិញទៀត នត្ថិភាព មានន័យថា ភាពគ្មាន ឬ ភាវៈដែលគ្មាន[40]។ លក្ខណៈនៃនត្ថិភាពនេះ គឺចង់សំដៅលើ ការដែលគ្មានសន្តតិជន។

#### ៣.១.១. ការបាត់បង់សិទ្ធិជាសន្តតិជន

ក្រោយពីបានពិនិត្យច្បាស់លាស់ថាបុគ្គលដែលបានអះអាងជាសន្តតិជនគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជនដូចមានចែងក្នុងក្រមរដ្ឋប្បវេណីទេ បុគ្គលនោះនឹងបាត់បង់សិទ្ធិជាសន្តតិជន។

---

[39] វចនានុក្រមសម្តេចសង្ឃរាជ *ជួន ណាត*។

[40] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និង នីតិត្រូសារ*, (ភ្នំពេញ៖ ជោគជ័យ, ឆ្នាំ២០១៧),៥៨៣។

### ៣.១.១.១.បុគ្គលដែលបាត់បង់ឬធ្លោះសិទ្ធិជាសន្តតិជន

មូលហេតុមួយចំនួនដែលនាំឲ្យបុគ្គលទាំងនោះបានធ្លោះសិទ្ធិជាសន្តតិជនដោយសារតែជាអភ័ព្វបុគ្គល និង ជាជនដែលត្រូវបានផ្តាច់មត៌កពីសន្តតិកម្ម។

**ក. អភ័ព្វបុគ្គល**

លក្ខខណ្ឌមួយចំនួនដែលបានសន្មតថាបុគ្គលនោះជាអភ័ព្វបុគ្គលនៃសន្តតិកម្មគឺ[41]៖

**ក.**បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នាទោះដោយផ្ទាល់ក្តី ដោយប្រយោលក្តី។ យោងតាមក្រមព្រហ្មទណ្ឌបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសឃាតកម្ម ឬ បទប៉ុនប៉ងឃាតកម្ម ទោះបីជាលើបុគ្គលណាក៏ដោយគឺត្រូវតែទទួលទោសព្រហ្មទណ្ឌហើយបទល្មើសនេះជាបទល្មើសមួយដ៏ធ្ងន់ធ្ងរ ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីវិញបើបុគ្គលនោះបានប្រព្រឹត្តបទឃាតកម្មចំពោះជនដែលបានរៀបរាប់ខាងលើគឺត្រូវបានបាត់បង់សិទ្ធិជាសន្តតិជន ហើយនឹងក្លាយជាអភ័ព្វបុគ្គលដែលមិនអាចទទួលបានមត៌កពីមតកជនបានឡើយ។ ទោះបីជាឃាតកម្មនោះបានធ្វើដោយផ្ទាល់ខ្លួនក្តី ឬ ដោយប្រយោលក្តី ឬ គ្រាន់តែមានការចូលដៃចូលជើងផ្សំគំនិតក្នុងរឿងឃាតកម្មនោះ ដើម្បីធ្វើឃាតមតកជនក្នុងគោលបំណងចង់បានទ្រព្យនោះយ៉ាងឆាប់រហ័ស ឬ ធ្វើឃាតលើសន្តតិជនលំដាប់ស្មើក្នុងគោលបំណងចង់បង្កើនទ្រព្យឲ្យបានច្រើន ឬ សន្តតិជនលំដាប់មុនក្នុងគោលបំណងដើម្បីក្លាយជាសន្តតិជន។

**ខ.**បុគ្គលណាដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង។ មានន័យថាបុគ្គលនោះមិនបានធ្វើសកម្មភាពសម្លាប់មតកជននោះទេ ប៉ុន្តែគាត់បានដឹងគ្រប់យ៉ាងពីការធ្វើឃាតហើយមិនហ៊ានប្តឹងដោយសារការភ័យខ្លាច ឬ ដើម្បីផលប្រយោជន៍ណាមួយ ឬ គាត់មិនអើពើនឹងសកម្មភាពក្នុងការធ្វើបណ្តឹងនោះដោយសារហេតុផលផ្សេង។ ផ្ទុយទៅវិញច្បាប់ក៏បានលើកលែងផងដែរ ទោះបីជាគាត់មិនបានប្តឹងក៏ដោយ ប្រសិនបើគាត់ជាជនដែលមានបញ្ហាខ្សោយខាងបញ្ញាស្មារតីដែលមិនអាចដឹង ឬ វិនិច្ឆ័យថា អំពើនោះជាការត្រឹមត្រូវ ឬ ខុស ឬ ដោយសារតែគាត់ជាសាច់លោហិតខ្សែផ្ទាល់ ឬ ជាសហព័ទ្ធនឹងគ្នាទៅនឹងបុគ្គលនោះ ព្រោះច្បាប់បានពិចារណាទៅលើមនោសញ្ចេតនាដែលស្ថិតក្នុងស្ថានភាពមួយពិបាកនឹងប្តឹង មិនត្រូវបានបាត់បង់សិទ្ធិជាសន្តតិជនឡើយ។

**គ.**ប្រសិនបើគេរកឃើញថាបុគ្គលណាដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬ គំរាមគំហែង។ ការរារាំងការធ្វើ លុបចោល ឬ កែប្រែ

[41] មាត្រា១១៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

មតកសាសន៍ស្តីពីសន្តតិកម្មដោយមានការឆបោក ឬ គំរាមគំហែងគឺជាអំពើខុសច្បាប់មួយដែលនាំឲ្យមតកសាសន៍នោះត្រូវបានអលទ្ធភាពអនុវត្តនៅពេលដឹងថាមតកជនត្រូវបានឆបោក ឬ គំរាមគំហែង ព្រោះវាជាមតកសាសន៍ដែលមិនបានកើតចេញពីឆន្ទៈផ្ទាល់របស់មតកជន ទោះបីជាស្ថិតក្នុងការប្រើប្រាស់មធ្យោបាយណាក៏ដោយដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន ហើយជននោះត្រូវបានក្លាយជាអភ័ព្វបុគ្គល ។

**ឃ.**បុគ្គលណាដែលបានឲ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬ គំរាមគំហែង វាមិនខុសពីការរារាំងឡើយដែលសុទ្ធតែជាមូលហេតុនាំឲ្យបុគ្គលបាត់បង់សិទ្ធិជាសន្តតិជន ប៉ុន្តែចំណុចនេះខុសពីចំណុចខាងលើត្រង់សកម្មភាពខាងលើគ្រាន់តែជាការរារាំងប៉ុណ្ណោះ តែការឲ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ជាអំពើមួយដែលជាការបង្ខិតបង្ខំមតកជនឲ្យគាត់តែងមតកសាសន៍តាមចិត្តដែលខ្លួនចង់បានដែលជាអំពើទុច្ចរិតអាក្រក់របស់សន្តតិជន។

**ង.** បុគ្គលដែលបាន ក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន ក្នុងគោលបំណងចង់បិទបាំងដើម្បីផលប្រយោជន៍ណាមួយ ឬ លេបត្របាក់យកមតិកស្ទើរតែទាំងស្រុងរបស់មតកជន ឬ មួយផ្នែកណាមួយរបស់សន្តតិជនណាមួយ ដើម្បីផលប្រយោជន៍ណាមួយជាអំពើមួយដែលធ្វើឲ្យជននោះបានប្រាសចាកសិទ្ធិជាសន្តតិជន។

### ខ. ការផ្តាច់មត៌កចេញពីសន្តតិកម្ម

ការផ្តាច់មតិកចេញពីសន្តតិកម្ម តាមច្បាប់មានពីររបៀប គឺ ការផ្តាច់មតិកចេញពីសន្តតិកម្មតាមតុលាការ និង ការផ្តាច់មតិកចេញពីសន្តតិកម្មដោយមតកសាសន៍ ។

- **ការផ្តាច់មតិកចេញពីសន្តតិកម្មតាមតុលាការ**

យោងតាមមាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី ប្រសិនបើតុលាការរកឃើញថា មតកជនពេលនៅរស់បានដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឲ្យតុលាការផ្តាច់មតិកពីសន្តតិជន ទោះបីជាសន្តតិជននោះមិនបានធ្វើឃាត ឬ អំពើណាមួយដែលនាំឲ្យបុគ្គលនោះក្លាយជាអភ័ព្វបុគ្គលក៏ដោយ ប្រសិនបើសន្តតិជននោះបានប្រព្រឹត្តនូវសកម្មភាពមួយចំនួនដូចជាការវាយធ្វើបាបលើមតកជនដូចជាការប្រើអំពើហិង្សា ឬ អំពើឃោឃៅណាមួយលើរូបរាងកាយរបស់មតកជន បើតាមសីលធម៌ទំនៀមទម្លាប់វាជាអំពើរមិលគុណចំពោះអ្នកមានគុណជាអំពើប្រាសចាកពីសីលធម៌ដែលគួរឲ្យស្អប់ខ្ពើម ចំពោះការមិនដឹងគុណនេះដែលគេតែងតែនិយាយថាជាកូនអកត្តញ្ញូ ដូចនេះច្បាប់មិនអនុញ្ញាតឲ្យបុគ្គលរូបនោះទទួលបានអ្វីឡើយចំពោះអំពើអាក្រក់ដែលខ្លួនបានសាងទៅលើមតកជន។

ការជេរប្រមាថយ៉ាងធ្ងន់ធ្ងរលើមតកជនក៏ជាអំពើមិនគប្បីមួយដែលសន្តតិជនមិនសាកសមនឹងទទួលបានមតិកពីមតកជន ជាមូលហេតុមួយដែលមតកជនអាចស្នើសុំទៅតុលាការដើម្បីផ្តាច់មតកសាសន៍ប្រសិនបើគាត់យល់ថា វាជាអំពើប្រមាថមួយដ៏ធ្ងន់ធ្ងរចំពោះរូបគាត់ ហើយគាត់មិនអាចទទួលយកបានឡើយ។ ពេលខ្លះសន្តតិជនអាចមកមើលថែទាំមតកជនបាននៅពេលគាត់មានជំងឺ ឬចាស់ជរាប៉ុន្តែសន្តតិជនបែរជាមិនបានមកមើលថែ ដោយទុកពួកគាត់ចោលមិនរវល់អ្វីទាំងអស់ ជាអំពើដែលខ្វះសីលធម៌មួយក្នុងសង្គមខ្មែរមិនឲ្យតម្លៃលើបុគ្គលនេះ ទោះបីមិនមែនជាអំពើខុសច្បាប់ ឬ ជាកាតព្វកិច្ចក៏ដោយ តែវាជាករណីយកិច្ចរបស់កូនម្នាក់ៗក្នុងការមើលថែពួកគាត់ពេលមានជំងឺ ឬ ចាស់ជរា ដែលជាមូលហេតុអាចឲ្យច្បាប់ដកហូតសិទ្ធិជាសន្តតិជនរបស់គាត់បាន។

សកម្មភាពមួយទៀតនៃការចេញសាលក្រម ឬ សាលដីការបស់ចៅក្រមក្នុងការផ្តន្ទាទោសសន្តតិជនឲ្យជាប់ពន្ធនាគារអស់មួយជីវិតក៏ជាមូលហេតុនៃការផ្តាច់មតកសាសន៍ផងដែរ ពីព្រោះជននេះបានបាត់បង់សិទ្ធិមួយចំនួនធំ ហើយច្បាប់មិនអនុញ្ញាតអោយគាត់កាន់កាប់ទ្រព្យអ្វីឡើយព្រោះគាត់គ្មានសេរីភាពពេញលេញ ហើយគាត់មិនអាចប្រើប្រាស់មតិកទាំងនោះឡើយទើបច្បាប់មិនតម្រូវឲ្យគាត់ទទួលបានមតិក។

ម៉្យាងវិញទៀតការប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរដែលជាការគួរឲ្យកត់សម្គាល់របស់មតកជនដូចជាការប្រើប្រាស់អំពើហិង្សាជាប្រចាំធ្វើឲ្យមតកជនមិនពេញចិត្តនឹងទង្វើនោះ ក៏ជាមូលហេតុដែលមតកជនអាចប្តឹងសុំផ្តាច់មតកសាសន៍បានដែរ។

គ្រប់សកម្មភាពទាំងអស់ខាងលើសុទ្ធតែអាចជាមូលហេតុនៃការផ្តាច់មតិកពីសន្តតិជនរបស់មតកជន ប៉ុន្តែមិនមែនមានន័យថាគ្រប់ការស្នើសុំដោយមូលហេតុខាងលើសុទ្ធតែអាចផ្តាច់មតកសាសន៍ពីសន្តតិជនបានឡើយគឺវាអាស្រ័យផងដែលទៅលើថា តើមតកជនមានបំណងចង់ផ្តាច់មតកសាសន៍ដោយអំពើទាំងនោះ ឬ ជាល្បិចកលផ្សេងៗរបស់មតកជន ដោយសារមូលហេតុការស្រលាញ់កូនមិនស្មើគ្នា ឬ ដោយសារតែជាកូនស្មុំ ដើម្បីឲ្យកូនបង្កើតរបស់ខ្លួនទទួលបានទ្រព្យទាំងអស់ដោយមិនចង់ចែកទ្រព្យទៅឲ្យកូនស្មុំដែលមិនមែនជាសាច់ញាតិលោហិតរបស់ខ្លួន ឬ ម៉្យាងទៀតត្រូវពិចារណាផងដែរ ប្រសិនបើការផ្តាច់មតកសាសន៍គឺគ្រាន់តែដោយសារការខឹងមួយឆាវរបស់មតកជនចំពោះសន្តតិជន ព្រោះមនុស្សចាស់បញ្ញាស្មារតីរបស់គាត់កាន់តែចុះខ្សោយ មិនអាចពិចារណាបាន ក៏ធ្វើការស្នើទៅតុលាការដោយយោងតាមមូលហេតុខាងលើ ក៏មិនត្រូវបានផ្តាច់ចេញពីមតកសាសន៍ឡើយ។

- **ការផ្តាច់មត៌កចេញពីសន្តតិកម្មដោយមតកសាសន៍**

យោងតាមមាត្រា ១១៥២ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមតកជនបានធ្វើមតកសាសន៍តាមមូលហេតុនៃមាត្រា ១១៥១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នេះដែលអាចជាមេធាវីជាដើមដែលបានដាក់ពាក្យសុំទៅតុលាការឲ្យផ្តាច់មត៌កពីសន្តតិជននោះដោយគ្មានការយឺតយ៉ាវនៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព ក្នុងករណីនេះវាមានអានុភាពចាប់ពីពេលដែលមតកជនបានទទួលមរណភាព ដូចនេះ នាំឲ្យបុគ្គលនោះបាត់បង់សិទ្ធិជាសន្តតិជន។

## ៣.២. ការបោះបង់សន្តតិកម្ម

កម្មវត្ថុនៃសន្តតិកម្ម គឺជាទ្រព្យផ្ទាល់របស់មតកជន ដែលអាចជាទ្រព្យដោយឡែក និង ១ភាគ២នៃទ្រព្យរួមរបស់មតកជនមានសហព័ទ្ធ ទ្រព្យរបស់មតកជនអាចជាចលនទ្រព្យ អចលនទ្រព្យ ប្រាក់នៅក្នុងគណនេយ្យធនាគារ សិទ្ធិលើបំណុល ឬ ជាបំណុលផ្សេងៗទៀត។ មិនតែប៉ុណ្ណោះ នៅពេលសន្តតិកម្មចាប់ផ្តើម គប្បីស្រាវជ្រាវ ឬ ស្វែងយល់ពីបំណុលរបស់មតកជនដើម្បីឲ្យមានភាពច្បាស់លាស់ថា តើបំណុលទាំងនោះមានកម្រិតណា ច្រើនជាង ឬ តិចជាងទ្រព្យដែលបន្សល់ទុកសម្រាប់ជាមូលដ្ឋានក្នុងការបង្ហាញឆន្ទៈក្នុងការទទួលយកដោយមានកម្រិត ឬ បោះបង់សន្តតិកម្ម។

### ៣.២.១. ការបោះបង់សន្តតិកម្ម

ការបោះបង់គឺជានីតិវិធីនៃការស្ម័យសម្រេចចិត្តរបស់សន្តតិជនតាមគោលបំណងរបស់ខ្លួនក្រៅពីនីតិវីធីនៃការទទួលស្គាល់។ ក្នុងរបបសន្តតិកម្ម ច្បាប់បានអនុញ្ញាតផ្តល់សិទ្ធិទៅជននឹងក្លាយជាសន្តតិជននេះឲ្យព្រមទទួលនូវសន្តតិកម្មនេះ ឬ សុខចិត្តបោះបង់ចោល។ ប្រសិនបើបោះបង់សន្តតិកម្ម បុគ្គលនេះនឹងលែងក្លាយទៅជាសន្តិជនហើយ ម្យ៉ាងទៀតសន្តតិជនជំនួសក៏មិនមានអានុភាពកើតឡើងដែរ ព្រោះបុគ្គលដែលបានបោះបង់សន្តតិកម្ម ច្បាប់ចាត់ទុកថាបុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក[42]។ ការបោះបង់ត្រូវមានគោលបំណងនិងមូលហេតុត្រឹមត្រូវ និងច្បាស់លាស់។ នីតិវិធីនេះត្រូវបានកើតឡើងនៅពេលដែលសល់បំណុលច្រើនជាងទ្រព្យសម្បត្តិសកម្មដែលនៅសល់នោះ សន្តតិជនអាចបោះបង់សន្តតិកម្មនេះបានដោយមិនត្រូវបានទទួលខុសត្រូវលើបំណុលនោះឡើយ។ ម្យ៉ាងវិញទៀត ការបោះបង់នេះក៏អាចកើតឡើងនៅពេលសន្តតិជនណាមួយព្រមលះបង់ចំណែករបស់ខ្លួនដើម្បីឲ្យសន្តតិជនផ្សេងមានសិទ្ធិទទួលបានចំណែករបស់ខ្លួន ឬ បុគ្គលនេះមិនចង់បាននូវចំណែកមត៌ក ក៏គេអាចធ្វើការបោះបង់ផងដែរ។ វាមិនត្រឹមត្រូវនោះទេ ប្រសិនបើសន្តតិកម្មនេះកើតឡើងដោយសារតែការបង្ខំឲ្យសន្តតិជនទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ច ជាពិសេសសន្តតិជននោះមិនចង់បានអ្វីសោះពីមតកជន ឬ ប្រសិនបើមតកជនមានកាតព្វកិច្ចលើ

[42] មាត្រា១២៦១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

បំណុលជាច្រើន ហើយការបង្ខំឲ្យសន្តតិជនទទួលបន្ទុកបំណុលនោះជារឿងមិនសមរម្យឡើយ។ ដូចនេះ ក្រមរដ្ឋប្បវេណីបានអនុញ្ញាតឲ្យសន្តតិជនធ្វើការបោះបង់សន្តតិកម្មបាន។

### ៣.២.១. នីតិវិធីនៃការបោះបង់

ចំពោះនីតិវិធីនៃការបោះបង់ មិនខុសពីនីតិវិធីនៃការទទួលស្គាល់នោះទេ គឺយោងតាមមាត្រា១២៤៨ នៃក្រមរដ្ឋប្បវេណី សន្តតិជនត្រូវធ្វើការបោះបង់នៅក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលដែលដឹងថាសន្តតិកម្មរបស់ខ្លួនត្រូវបានចាប់ផ្តើម។ នេះជារយៈពេលមួយនៃការគិតពិចារណាថាព្រមទទួលស្គាល់ ឬ បោះបង់ ហើយក៏ជាពេលមួយដែលអាចសិក្សាលើចំនួននៃចំណែកមតិកនៅសល់នេះមានទំហំប៉ុណ្ណា បើសិនវាមានទំហំតូចជាងបំណុលនោះសន្តតិជននឹងធ្វើការបោះបង់សិទ្ធិជាសន្តតិជននៃចំណែកនេះយ៉ាងពិតប្រាកដ។ ការដាក់ពាក្យស្នើសុំបោះបង់សន្តតិកម្មត្រូវធ្វើដោយសន្តតិជនម្នាក់ៗដាក់ទៅកាន់តុលាការ ដើម្បីបង្កើតអានុភាពនៃការបោះបង់ (មាត្រា១២៦០ នៃក្រមរដ្ឋប្បវេណី)។ អ្នកដាក់ពាក្យស្នើសុំនេះក៏មិនត្រូវចាំបាច់មានការយល់ព្រមពីសន្តតិជនដទៃទៀតក្នុងការបោះបង់សន្តតិកម្មនេះដែរ។ ក្រោយពីមានពាក្យសុំបោះបង់របស់សន្តតិជន តុលាការត្រូវពិនិត្យថាអ្នកដាក់ពាក្យនេះមានបំណង ឬ មានមូលហេតុច្បាស់លាស់ក្នុងការបោះបង់សន្តតិកម្មដែរ ឬ ទេ? ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវ ឬ ភាពចាំបាច់ វាមិនមែនជាលក្ខខណ្ឌក្នុងការបោះបង់សន្តតិកម្មនោះទេ។ រយៈពេល៣ខែនេះក៏អាចពន្យាពេលបានដែរ បើសន្តតិជនត្រូវការពេលវេលាក្នុងការសម្រេចចិត្ត ប៉ុន្តែគឺត្រូវធ្វើពាក្យសុំទៅតុលាការ[43]។

ប្រសិនបើតុលាការសម្រេចឲ្យសន្តតិជនបោះបង់សន្តតិកម្ម នោះរបបសន្តតិកម្មនឹងចាត់ទុកថានត្ថិភាពនៃសន្តតិជន។

## ៣.៣. ការចាត់ចែងមត៌ក

បន្ទាប់ពីនីតិវិធីស្វែងរកសន្តតិជន ហើយបានបញ្ជាក់យ៉ាងច្បាស់អំពីនត្ថិភាពនៃសន្តតិជននោះ ការចាត់ចែងមតិកនេះគឺអ្នកគ្រប់គ្រងធ្វើការសងបំណុល និង អច្ច័យទានចេញពីមតិក និង ចែកទៅជនមាននិស្ស័យពិសេស ឬ ធ្លាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ។

### ៣.៣.១. សិទ្ធិ និង ភារកិច្ចរបស់អ្នកគ្រប់គ្រង

អ្នកជ្រើសតាំងអ្នកគ្រប់គ្រងពិតជាមានសារៈសំខាន់ណាស់ព្រោះអ្នកគ្រប់គ្រងគឺជាបុគ្គលដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្នរបស់មតកជនទម្រាំដល់ពេលចាត់ចែងទ្រព្យទៅតាមនីតិវិធីពីព្រោះទ្រព្យសម្បត្តិទាំងអស់មិនអាចទុកចោលដោយគ្មាន

[43] មាត្រា១២៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

អ្នកទុកដាក់បានឡើយ។ យោងតាមមាត្រា១២៩២ នៃក្រមរដ្ឋប្បវេណី កាតព្វកិច្ចរបស់អ្នកគ្រប់គ្រង មានដូចជា៖

- អ្នកគ្រប់គ្រងត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងទៅនឹងមតិក ដោយគ្មានការយឺតយ៉ាវ គឺមានន័យថាអ្នកគ្រប់គ្រងត្រូវធ្វើបញ្ជីមួយទាក់ទងទៅនឹងការចំណាយ ឬ សកម្មភាពប្រើប្រាស់ផ្សេងៗទៀតដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់មតកជន ឲ្យបានច្បាស់លាស់អំពីព័ត៌មានទាំងអស់នៃទ្រព្យ រាល់បញ្ជីសារពើភ័ណ្ឌមិនត្រូវធ្វើឲ្យមានការយឺតយ៉ាវឡើយព្រោះវាអាចធ្វើឲ្យបាត់ទិន្នន័យណាមួយដែលប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យ។
- អ្នកគ្រប់គ្រងត្រូវថែរក្សាគ្រប់គ្រងមតិកនោះឲ្យដូចជាមតិករបស់ខ្លួនមិនត្រូវធ្វេសប្រហែសឡើយ។ ប្រសិនបើមិនមានការចាំបាច់ទេក្នុងការថែរក្សា និង គ្រប់គ្រងមតិកនោះអ្នកគ្រប់គ្រងអាចស្នើសុំទៅតុលាការដើម្បីប្តូរមតិកនោះជាប្រាក់ ឬ អាចចាត់ចែងទ្រព្យនោះទៅតាមតម្រូវការចាំបាច់ប្រសិនបើមានការអនុញ្ញាតពីតុលាការ។
- ក្នុងករណីដែលមានការទាមទារបំណុលពីម្ចាស់បំណុល ឬ អច្ច័យលាភីនោះ អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានការណ៍នៃទ្រព្យសម្បត្តិទៅឲ្យជននោះ។
- ទាក់ទងទៅនឹងបំណុលអ្នកគ្រប់គ្រងត្រូវអនុវត្តតាមចំណុចនីមួយៗដូចគ្នានៃកាតព្វកិច្ចរបស់អ្នកយល់ព្រមដោយកម្រិតដែលមានចែងចាប់ពីមាត្រា១៩៨២ ដល់មាត្រា១៩៨៦ នៃក្រមរដ្ឋប្បវេណី សិទ្ធិរបស់អ្នកគ្រប់គ្រងក្នុងការបដិសេធការសងនៅអំឡុងពេលដាស់តឿន ឬ ករណីដែលម្ចាស់បំណុលមិនបានស្នើសុំ ហើយកាតព្វកិច្ចរបស់អ្នកគ្រប់គ្រងក៏អនុវត្តដូចគ្នាផងដែលទាក់ទងទៅនឹងការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនដល់ម្ចាស់បំណុលជាអាទិ៍ដែលមានចែងក្នុងមាត្រា១២៩៦។
- តាមរយៈការបង្គាប់របស់តុលាការ អ្នកគ្រប់គ្រងត្រូវស្រាវជ្រាវអំពីអង្គហេតុ ហើយត្រូវធ្វើសេចក្តីរាយការណ៍នៃលទ្ធផលនោះទៅតុលាការជាចាំបាច់។

### ៣.៣.២. កម្រៃសម្រាប់អ្នកគ្រប់គ្រង

យ៉ាងណាមិញ អ្នកគ្រប់គ្រងបានចំណាយពេលវេលានិងកម្លាំងកាយដើម្បីថែរក្សាមតិកឲ្យមតកជន ប្រសិនបើគ្មានអ្នកគ្រប់គ្រងមើលថែទ្រព្យសម្បត្តិទាំងអស់នោះទេ តុលាការក៏ពិបាកក្នុងការបែងចែកមតិកឲ្យបានត្រឹមត្រូវដែរ អ្នកគ្រប់គ្រងបានជួយសម្រួលការងារនៃការបែងចែកមតិកនេះឲ្យកាន់តែងាយស្រួល ដែលជាការសម្រួលការងារតុលាការបានមួយផ្នែក។ ហេតុដូចនេះហើយតុលាការអាចផ្តល់កម្រៃសមរម្យ ដែលចេញអំពីក្នុងចំណោមមតិកនោះ ឲ្យទៅអ្នកគ្រប់គ្រងបាន

ដោយគិតពិចារណាអំពីស្ថានភាពនៃមតិក និង សកម្មភាពផ្សេងៗ[44]របស់អ្នកគ្រប់គ្រងដែលបានធ្វើដើម្បីថែរក្សាមតិកឲ្យបានល្អ ដែលសាកសមទៅនឹងកម្លាំងញើសឈាមរបស់អ្នកគ្រប់គ្រង។

**៣.៣.៣. នត្ថិភាពមិនធ្វើឲ្យរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង**

សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងមិនត្រូវបានរលត់ទេ ទោះបីមានសន្តតិជនក៏ដោយ ព្រោះបើសន្តតិជនមិនព្រមទទួលស្គាល់សន្តតិកម្ម ហើយធ្វើការបោះបង់ នោះគេចាត់ទុកថា នត្ថិភាពនៃសន្តតិជន។ ហេតុនេះ សិទ្ធិអំណាចនៃការគ្រប់គ្រងមតិកដោយអ្នកគ្រប់គ្រងគឺនៅដដែលរហូតដល់ការគ្រប់គ្រងតាមនីតិវិធីត្រូវបានបញ្ចប់។

**៣.៣.៤. ការចាត់ចែងទ្រព្យទៅឲ្យជនមាននិស្ស័យពិសេស**

ប្រសិនបើនៅតែគ្មានការស្នើសុំពីសន្តតិជន ឬ មិនរកឃើញសន្តតិជននោះទេ អ្នកគ្រប់គ្រងត្រូវចាត់ចែងទ្រព្យសម្បត្តិដែលនៅសល់ក្រោយសងបំណុល។ យោងតាមក្រមរដ្ឋប្បវេណី បានចែងអំពីការបែងចែកមតិកទៅឲ្យអ្នកមាននិស្ស័យពិសេស គឺត្រង់មាត្រា១២៩៩ ដែលអ្នកមាននិស្ស័យពិសេសគឺជនដែលមានទំនាក់ទំនងជាមួយមតកជន ដែលបានខិតខំមើលថែទាំពេលមតកជនកំពុងឈឺ ឬ ជនដទៃទៀតដែលមានភាពស្និទ្ធស្នាលជាមួយមតកជនកាលនៅរស់ ប៉ុន្តែជនដែលបានអះអាងថាខ្លួនជាអ្នកមាននិស្ស័យពិសេសគឺត្រូវតែដាក់ពាក្យស្នើសុំអំពីសមាសភាពរបស់ខ្លួន។ ជនមាននិស្ស័យពិសេសអាចជាជនដែលរួមរស់ជីវភាពជាមួយមតកជន ដូចជា[45]៖

- ប្តីប្រពន្ធអនីតិសង្វាស
- ក្មួយប្រុស ក្មួយស្រី និង ពូ មីង ដែលរស់នៅជាមួយគ្នាដូចឪពុកម្តាយ និង កូន
- កូនចុង ឬ ឪពុកម្តាយចុង។

ជនដែលបានខិតខំមើលថែមតកជនមានដូចជា មេផ្ទះ គិលានុបដ្ឋាយិកា បងប្អូនសាច់ឆ្ងាយ ឬ អ្នកធ្វើការងារសង្គម ជាដើម។ បើក្នុងករណីដែលពួកគេទាំងនេះទទួលបានការបង់ប្រាក់ នោះនឹងមានការលំបាកនៅក្នុងការកំណត់ថាពួកគេជាជនដែលមាននិស្ស័យពិសេសនេះ។ ប៉ុន្តែ ប្រសិនបើពួកគេខំប្រឹងប្រែងធ្វើការងារយ៉ាងនឿយហត់ជាងបងប្អូនធម្មតាធ្វើទៀតនោះ ពួកគេអាចសាកសមនឹងត្រូវបានចាត់ទុកជាជនដែលមាននិស្ស័យពិសេស[46]។

---

[44] មាត្រា១២៩៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

[45] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣* (ភ្នំពេញ៖ គម្រោងអភិវឌ្ឍវិស័យច្បាប់ និង តុលាការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), ២០១៧), ១០៩។

[46] ដូច៤៥។

ការស្នើសុំរបស់អ្នកមាននិស្ស័យពិសេសនេះ គឺត្រូវធ្វើក្នុងអំឡុងពេល៣ខែ ក្រោយពីអំឡុងពេលការជូនដំណឹងជាសាធារណស្វែងរកសន្តតិជនបានកន្លងហួស។ ប្រសិនបើតុលាការពិចារណាឃើញថា សមហេតុផលទៅលើអង្គហេតុដូចជា[47]៖

- តើបុគ្គលនោះគឺជាសាច់ញាតិរបស់មតកជនដែរ ឬ ទេ?
- តើបុគ្គលនោះបាននឹងកំពុងរស់នៅជាមួយមតកជនដែរ ឬ ទេ?
- តើបុគ្គលនោះបានទៅសួរសុខទុក្ខមតកជននៅឯមន្ទីរពេទ្យប៉ុន្មានដងដែរ?
- តើបុគ្គលនោះបានផ្តល់ការមើលថែទាំប្រភេទណាដល់មតកជន?
- តើជំនួយហិរញ្ញវត្ថុប្រភេទណាដែលបុគ្គលនោះបានផ្តល់ទៅឲ្យមតកជនដូចជា សោហ៊ុយចំណាយចូលមណ្ឌលមើលថែចាស់ជរា ការដាក់ពាក្យសុំទទួលការព្យាបាលក្នុងមន្ទីរពេទ្យ ឬ ការដាក់ពាក្យសុំទទួលជំនួយហិរញ្ញវត្ថុសាធារណៈ និង ការរៀបចំពិធីបុណ្យសព ជាដើម។
- តើអ្វីជាឆន្ទៈរបស់មតកជន?

នោះតុលាការអាចចេញសេចក្តីសម្រេចប្រគល់ឲ្យនូវផ្នែកនៃមតិកដែលនៅសល់ទៅជនមាននិស្ស័យពិសេស។ ការស្នើសុំនេះមិនមែនចេះតែស្នើបានសម្រេចគ្រប់នោះទេ ដរាបណាមានការបញ្ជាក់ឲ្យបានច្បាស់អំពីស្ថានភាព ឬ សកម្មភាព ឬ ភស្តុតាងបញ្ជាក់ថា ជនដែលស្នើសុំនេះពិតជាសាកសមជាអ្នកមាននិស្ស័យពិសេសពិតមែន ម្យ៉ាងទៀត ដើម្បីឲ្យការស្រាវជ្រាវនេះពិតជាត្រឹមត្រូវ តុលាការនឹងធ្វើការសួរយោបល់ពីអ្នកដែលដឹងឮ ជាពិសេសគឺមេឃុំ ចៅសង្កាត់ ឬ សាក្សីផ្សេងដែលអាចបញ្ជាក់បាន។ ទ្រព្យដែលនឹងចែកជូនទៅអ្នកមាននិស្ស័យពិសេស គឺចំនួនសរុបដែលចែកឲ្យមិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមតិកដែលនៅសេសសល់ទេ[48]។

### ៣.៣.៥. មត៌កធ្លាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ

ផ្ទុយមកវិញ ប្រសិនបើមិនមានវត្តមានអ្នកមាននិស្ស័យពិសេសទេ ទ្រព្យដែលសេសសល់នេះនឹងក្លាយជាទ្រព្យរបស់រដ្ឋ[49]។ ក្រៅពីនេះ ប្រសិនបើមិនមានសន្តតិជននោះទេ មតិកនោះត្រូវក្លាយជានីតិបុគ្គល[50]។ ដោយហេតុនេះ មតិកនឹងធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ ព្រោះទ្រព្យសម្បត្តិនេះមិនមានអ្នកគ្រប់គ្រង ឬ មិនមានអ្នកណាដែលអាចធ្វើជាម្ចាស់កម្មសិទ្ធិបាន។ តាមមាត្រា ១៦១ នៃ

[47] ដូច៨៥ ទំព័រ ១១០។
[48] មាត្រា១២៩៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[49] មាត្រា១៣០០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[50] មាត្រា១២៩០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ក្រមរដ្ឋប្បវេណី ចំពោះទ្រព្យណាដែលជាអចលនវត្ថុដែលគ្មានកម្មសិទ្ធិករ នោះអចលនវត្ថុនេះធ្លាក់ជាទ្រព្យរបស់រដ្ឋ ដែលរដ្ឋជាម្ចាស់កម្មសិទ្ធិករ។ ដោយឡែកចំពោះទ្រព្យសម្បត្តិដែលជាចលនវត្ថុតាមមាត្រា១៨៨ នៃក្រមដដែលបានចែងថា ចលនវត្ថុណាដែលត្រូវបានគេកាន់កាប់មុន ជនម្នាក់នេះនឹងក្លាយជាកម្មសិទ្ធិករនៃវត្ថុនេះតែម្តង។ ប៉ុន្តែបើមិនមានអ្នកកាន់កាប់មុនទេ ក៏ចលនវត្ថុនេះក៏ធ្លាក់ទៅជារបស់រដ្ឋផងដែរ។

### ៣.៤. ករណីនត្តិភាពនៃសន្តតិជននៅសហរដ្ឋអាមេរិក

មានអត្ថបទមួយសរសេរដោយ មេធាវីឈ្មោះ Jason W. Stern ជាមេធាវីដោះស្រាយរឿងក្តីទាក់ទងនឹងអចលនទ្រព្យ បានសរសេររឿងក្តីមួយកើតឡើងនៅប្រទេសសហរដ្ឋអាមេរិក ដែលនិយាយអំពីបុគ្គលម្នាក់បានទទួលមរណភាពហើយមិនបានបន្សល់ទុកបណ្តាំទេ ព្រមទាំងមិនមានសាច់ញាតិដែលអាចក្លាយជាសន្តតិជនបាន។ មតកជននេះមានឈ្មោះថា Roman Blum កើតនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩១៤ នៅឯប្រទេសប៉ូឡូញ។ នៅគ្រាសម័យសង្គ្រាម ប្រទេសប៉ូឡូញត្រូវបានឈ្លានពានដោយណាស៊ី ប្រទេសអាល្លឺម៉ង់។ លោក Roman Blum ត្រូវបានបាត់បង់ប្រពន្ធនិងកូនប្រុសរបស់គាត់ រីឯរូបគាត់ត្រូវបានរួចផុតនៅរស់រានមានជីវិត និង ត្រូវបានរំដោះនៅខែ ឧសភា ឆ្នាំ ១៩៤៥។ ក្រោយមកទៀត គាត់បានជួបនារីម្នាក់ហើយបានរៀបការជាលើកទី២ ព្រមទាំងនាំគ្នាមករស់នៅប្រទេសសហរដ្ឋអាមេរិក នៅឆ្នាំ១៩៤៩ ដែលគាត់កសាងលំនៅឯ Forest Hills, New York ប៉ុន្តែក្រោយមក គាត់ក៏បានផ្លាស់លំនៅទៅ Staten Island, New York វិញ។ គាត់បានក្លាយជាសហគ្រិនលើវិស័យអចលនទ្រព្យដ៏ជោគជ័យម្នាក់ដែលមានទ្រព្យសម្បត្តិជាច្រើនបន្សល់ទុក។ ប៉ុន្តែនៅឆ្នាំ ១៩៩២ ភរិយាទី២របស់គាត់បានទទួលមរណភាព ដោយមិនបានបន្សល់ទុកកូនជាមួយគាត់ទេ។ ចុងក្រោយ លោក Roman Blum ក៏បានទទួលមរណភាពនៅខែមករា ឆ្នាំ ២០១២ ក្នុងអាយុ ៩៧ឆ្នាំ។ គាត់បានបន្សល់មត៌ករបស់គាត់ចំនួន ៤០ លានដុល្លារសហរដ្ឋអាមេរិក[51]។

តាមនីតិវិធីនៃរបបសន្តតិកម្ម បើមតកជនដឹងថាមិនមានសន្តតិជនទេ គាត់អាចធ្វើមតកសាសន៍ដើម្បីបែងចែកមត៌ករបស់គាត់ទៅជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬ បរិច្ចាគទៅអង្គការសប្បុរសធម៌តាមការសម្រេចចិត្តរបស់គាត់។ ចំណែកករណីរបស់លោក Roman Blum វិញ គាត់មិនបានធ្វើមតកសាសន៍ទេ ដើម្បីដោះស្រាយរឿងនេះ ជាដំបូងមេធាវីនៃ ការិយាល័យរដ្ឋបាល

[51] Jason W. Stern, *What Happens When A Holocaust Survivor Dies With $40,000,000.00, No Will Or Known Living Relatives? Kinship Dilemma; Estate Of Roman Blum,* http://www.queensestatelaw.com/2013/05/01/what-happens-when-a-holocaust-survivor-dies-with-40000000-00-no-will-or-known-living-relatives-kinship-dilemma-estate-of-roman-blum/?fbclid=IwAR3FNgRbG0q5u_WeHcUISA5ZfzVu6EiLXni9vumJUafUCqYt5VyE8Ef4SP8 (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

សាធារណៈ (The Public Administrator's Office) នៃតំបន់ទីក្រុង Staten Island បានធ្វើបញ្ជីសារពើភ័ណ្ឌលំអិតអំពីទ្រព្យសម្បត្តិទាំងអស់របស់គាត់ បន្ទាប់មកក៏បានធ្វើការស្វែងរកសាច់ញាតិណាដែលនៅរស់រានមានជីវិត។ ប្រសិនបើមានសាច់ញាតិនៅរស់ គេនឹងត្រូវធ្វើការបង្ហាញខ្លួននិងធ្វើការបញ្ជាក់អំពីភស្តុតាងនានាដែលអាចបញ្ជាក់អំពីទំនាក់ទំនងជាមួយនឹងមតកជន នោះមេធាវីនឹងធ្វើការត្រួតពិនិត្យលើឯកសារទាំងនេះ ព្រមទាំងរកសាក្សីដែលអាចបញ្ជាក់បាន។ ប៉ុន្តែគួរឲ្យសោកស្តាយ មិនមានបុគ្គលណាមកអះអាងថាជាសន្តតិជនទេ នេះគេអាចសន្មតថាមិនមានសាច់ញាតិនៅរស់រានមានជីវិតឡើយ។ ហេតុដូចនេះ ទ្រព្យសម្បត្តិរបស់មតកជននឹងធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ[52]។

គួរបញ្ជាក់ផងដែលថា The Public Administrator's Office គឺជាទីកន្លែងដែលមន្ត្រីស៊ីវិលបម្រើការទាក់ទងនឹងការគ្រប់គ្រងកិច្ចការរបស់មតកជនដូចជា ការពារ រៀបចំ គ្រប់គ្រង និងចាត់ចែងមតិកនៅក្នុងករណីដែលមតកជនមិនបានបន្សល់ទុកមតកសាសន៍ ឬ គ្មានសន្តតិជនមកបន្តនូវសិទ្ធិនេះ។ ទោះជាយ៉ាងនេះក្តី មនុស្សគ្រប់គ្នាសង្ឃឹមថានឹងមិនប្រើប្រាស់នូវសេវាកម្មមួយនេះទេ ដោយសារតែមិនចង់ឲ្យអ្នកដទៃមកគ្រប់គ្រងមតិករបស់ខ្លួន ដូចនេះមេធាវីតែងតែពន្យល់ឲ្យម្ចាស់ទ្រព្យសម្បត្តិត្រូវមានការរៀបចំផែនការចាត់ចែងអចលនទ្រព្យរបស់ខ្លួនដោយប្រគល់ទៅអ្នកមានទំនាក់ទំនងនឹងផលប្រយោជន៍ មិត្តភក្តិ ឬ សាច់ញាតិ ឬ រៀបចំមតកសាសន៍ទុកជាមុន ប៉ុន្តែជួនកាលវាមានភាពលំបាកក្នុងការចាត់តាំងនរណាម្នាក់មកបន្តនូវសិទ្ធិនេះ ព្រោះមតកជនមិនមានសាច់ញាតិ ឬ មិនមានមិត្តភក្តិណាមកយកចិត្តទុកដាក់លើរឿងគ្រួសាររបស់ខ្លួនដែលអាចក្លាយជាបន្ទុកលើគេ[53]។ ក្នុងករណីដែលមតកជនមិនបានបន្សល់ទុកមតកសាសន៍ មតិករបស់គាត់នឹងត្រូវបានអនុវត្តដោយច្បាប់ Intestacy Law ដែលជាច្បាប់ទាក់ទងនឹងមតកជនមិនបានបន្សល់ទុកនូវមតកសាសន៍ក្រោយទទួលមរណភាព មានន័យថាតុលាការនឹងសម្រេចឲ្យបុគ្គលជាសាច់ញាតិ

---

[52] Jason W. Stern, *What Happens When A Holocaust Survivor Dies With $40,000,000.00, No Will Or Known Living Relatives? Kinship Dilemma; Estate Of Roman Blum,* http://www.queensestatelaw.com/2013/05/01/what-happens-when-a-holocaust-survivor-dies-with-40000000-00-no-will-or-known-living-relatives-kinship-dilemma-estate-of-roman-blum/?fbclid=IwAR3FNgRbG0q5u_WeHcUISA5ZfzVu6EiLXni9vumJUafUCqYt5VyE8Ef4SP8 (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

[53]Cori A. Robinson, *The Office Of The Public Administrator: An Important Government Office, Albeit One You Hope To Never Have To Use, https://abovethelaw.com/2019/03/the-office-of-the-public-administrator-an-important-government-office-albeit-one-you-hope-to-never-have-to-use/?fbclid=IwAR1bxONVxH7YNiOmh5Kge-NaiD2EYh85xMSYY3Qrq2KEddmz_NqLqDAxdFc,*(ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

របស់មតកជនដើម្បីមកបន្តនូវកាតព្វកិច្ចគ្រប់គ្រងមតិកពីមតកជន។ តាមច្បាប់ គេជ្រើសរើសសាច់ញាតិមកបន្តនូវសិទ្ធិនេះតាមរយៈតារាងនៃញាតិ (Table of Consanguinity) ដូចខាងក្រោមនេះ[54]៖




54 David Shulman, *Man Dies With $40 Million, No Will, And No Heirs,* https://www.ginsbergshulman.com/blog/40milnowil/?fbclid=IwAR17djhODlo0qIqaUTUuRB3OaB_656MhtAw3xwIHMZj5q_qRKUDv5sBxe5A,(ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

ប៉ុន្តែបើសន្តតិជននោះបោះបង់នូវសិទ្ធិជាសន្តតិជន ឬ គ្មានសន្តតិជនទេ នោះ The Public Administrator's Office នឹងបន្តនូវកាតព្វកិច្ចនេះ ហើយមតិកធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ[55]។

ក្នុងករណីនេះបានឆ្លុះបញ្ចាំងអំពីភាពខុសគ្នា និង ភាពដូចគ្នារវាងនីតិវិធីរបស់ប្រទេសសហរដ្ឋអាមេរិក និង ប្រទេសកម្ពុជា គឺខុសគ្នាត្រង់ថា ទោះបីមិនមានមតកសាសន៍ក៏ច្បាប់ខ្មែរបានផ្តល់សិទ្ធិឲ្យជនមាននិស្ស័យពិសេសធ្វើការស្នើសុំទៅតុលាការដើម្បីទទួលបានមតិកខ្លះពីមតកជន ប៉ុន្តែចំពោះប្រទេសគេ ទាល់តែមតកជនបានបញ្ជាក់នៅក្នុងមតកសាសន៍ថាឲ្យទៅនរណាទើបមិត្តភក្តិរបស់ខ្លួនមានសិទ្ធិទទួលមតិកនេះ។ ចំណែកចំណុចដូចគ្នាគឺ ការស្វែងរកសន្តតិជនគឺត្រូវតែមានដើម្បីឲ្យសន្តតិជនមកបន្តនូវសិទ្ធិនិងកាតព្វកិច្ចនេះ។ ម្យ៉ាងទៀត ប្រទេសកម្ពុជាមានការជ្រើសតាំងអ្នកគ្រប់គ្រងដើម្បីមកការពារ និង គ្រប់គ្រងមតិកជាបណ្តោះអាសន្ន ប្រៀបបីដូចជាប្រទេសគេដែលមាន The Public Administrator's Office ជាអ្នកគ្រប់គ្រងមតិកជំនួសជាបណ្តោះអាសន្នដែរ។

[55] Cori A. Robinson, *The Office Of The Public Administrator: An Important Government Office, Albeit One You Hope To Never Have To Use*, *https://abovethelaw.com/2019/03/the-office-of-the-public-administrator-an-important-government-office-albeit-one-you-hope-to-never-have-to-use/?fbclid=IwAR1bxONVxH7YNiOmh5Kge-NaiD2EYh85xMSYY3Qrq2KEddmz_NqLqDAxdFc*,(ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការស្រាវជ្រាវលើប្រធានបទខាងលើស្តីអំពី **អត្ថិភាព និង នត្ថិភាពនៃសន្តតិជន** រួចមក អាចសន្និដ្ឋានបានថា របបសន្តតិកម្មនៅកម្ពុជា គឺមានតាំងពីសម័យបុរាណដែលវិធានគតិយុត្តមានការវិត្តទាក់ទងនឹងរបបសន្តតិកម្មពីវិធានបវេណីមកជាវិធានសរសេរ ពីឥទ្ធិពលវិធានគតិយុត្តឥណ្ឌាចិន មកជាវិធានគតិយុត្តរ៉ូម៉ាំង។ បច្ចុប្បន្ន ការបើករបបសន្តតិកម្មគឺត្រូវអនុវត្តស្របតាមច្បាប់ដែលមានចែង ខុសពីសម័យមុនដែលមិនមានច្បាប់សរសេរតាក់តែងឲ្យច្បាស់លាស់ឡើយ។ ក្នុងរបបសន្តតិកម្មនាពេលបច្ចុប្បន្ន គឺសន្តតិជនជាអ្នកបន្តនូវសិទ្ធិនិងកាតព្វកិច្ចពីមតកជន ប៉ុន្តែប្រសិនបើមតកជនកាលនៅរស់ពុំបានតាក់តែងមតិក ឬ មិនដឹងច្បាស់អំពីសន្តតិជនវិញ គឺវាជាបញ្ហាមួយដែលមានភាពស៊ាំញ៉ាំពិបាកនឹងដោះស្រាយ។ ហេតុនេះហើយ ក្រោយមរណភាពនៃមតកជនរួចមក នាំឲ្យមាននីតិវិធីមួយកើតឡើងគឺ ការស្វែងរកសន្តតិជន ដែលត្រូវធ្វើឡើងជាបីដំណាក់កាលតាមរយៈការជូនដំណឹងជាសាធារណៈដោយតុលាការ។ បើការប្រកាសនេះ មានការបង្ហាញខ្លួនពីបុគ្គលដែលអះអាងថាជាសន្តតិជន នោះតុលាការនឹងធ្វើការពិនិត្យលើភស្តុតាងដែលអាចបញ្ជាក់ថាពិតជាសន្តតិជនប្រាកដមែន ហើយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមច្បាប់កំណត់ដែលអាចក្លាយជាសន្តតិជនបាន ដោយមានលក្ខខណ្ឌដូចដែលបានរៀបរាប់នៅក្នុងជំពូកទី២ ខាងលើ ហើយបុគ្គលនោះបានធ្វើការទទួលស្គាល់សន្តតិកម្មតាមរយៈការយល់ព្រមទាំងស្រុង និង ការយល់ព្រមដោយកម្រិត នាំឲ្យបុគ្គលនោះនឹងក្លាយជាជនដែលត្រូវបន្តនូវសិទ្ធិ និង កាតព្វកិច្ចបន្តពីមតកជនតាមផ្លូវច្បាប់។

ការអនុវត្តនីតិវិធីស្វែងរកសន្តតិជនគឺមានភាពស្មុគស្មាញដែលត្រូវចំណាយរយៈពេលជាច្រើនក្នុងការអនុវត្ត។ ជាក់ស្តែង នៅសហរដ្ឋអាមេរិក ការបែងចែកមតិក (ក្នុងករណីនត្ថិភាពនៃសន្តតិជន) ដូចគ្នានឹងប្រទេសកម្ពុជាត្រង់ មាននីតិវិធីស្វែងរកសន្តតិជនដូចគ្នា និង មានការជ្រើសរើសអ្នកគ្រប់គ្រងដើម្បីមកការពារទ្រព្យសម្បត្តិរបស់មតកជនបណ្តោះអាសន្នដែរ[56] ហើយមតិកក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ[57] (ក្នុងករណីពុំមានសន្តតិជន) ក្រោយពីការបែងចែកដូចគ្នាទៅនឹងច្បាប់របស់ប្រទេសកម្ពុជាដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួនត្រង់ នៅសហរដ្ឋអាមេរិកប្រសិនបើគ្មានការបញ្ជាក់នៅក្នុងមតកសាសន៍ទេ ជនមាននិស្ស័យពិសេសមិនអាចស្នើសុំតុលាការដើម្បីទទួលបាន

[56] Cori A. Robinson, *The Office Of The Public Administrator: An Important Government Office, Albeit One You Hope To Never Have To Use*, https://abovethelaw.com/2019/03/the-office-of-the-public-administrator-an-important-government-office-albeit-one-you-hope-to-never-have-to-use/?fbclid=IwAR1bxONVxH7YNiOmh5Kge-NaiD2EYh85xMSYY3Qrq2KEddmz_NqLqDAxdFc,(ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

[57] David Shulman, *Man Dies With $40 Million, No Will, And No Heirs*, https://www.ginsbergshulman.com/blog/40milnowil/?fbclid=IwAR17djhODlo0qIqaUTUuRB3OaB_656MhtAw3xwIHMZj5q_qRKUDv5sBxe5A,(ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

មតិកមួយចំនួនបានទេ។ មួយវិញទៀត ការស្វែងរកសន្តតិជននៅសហរដ្ឋអាមេរិកធ្វើឡើងដោយមេធាវីនៃ The Public Administrator's Office[58] ដែលមិនមែនជាតួនាទីរបស់តុលាការដូចប្រទេសកម្ពុជាឡើយ។ នេះបានបង្ហាញឲ្យឃើញថា ការស្វែងរកសន្តតិជននៅសហរដ្ឋអាមេរិក គឺជាតួនាទីរបស់មេធាវីនៃការិយាល័យរដ្ឋបាលសាធារណៈជាអ្នកដោះស្រាយបញ្ហាមួយនេះ រីឯតុលាការនៅប្រទេសគេមិនមានតួនាទីឡើយ នេះហើយជាចំណុចគួរឲ្យកត់សម្គាល់ដែលខុសប្លែកខ្លាំងពីប្រទេសកម្ពុជា ដែលតុលាការកម្ពុជាទទួលបន្ទុកជាអ្នកដោះស្រាយលើបញ្ហានេះ។ រីឯនៅប្រទេសបារាំងវិញ សារការីមានតួនាទីសំខាន់ក្នុងការអនុវត្តនីតិវិធីផ្សេងៗទាក់ទងនឹងរបបសន្តតិកម្ម ជាពិសេស ការកំណត់អត្តសញ្ញាណរបស់សន្តតិជនគឺសារការីជាអ្នកត្រួតពិនិត្យថា បុគ្គលនោះជាសន្តិជនពិតប្រាកដដែរ ឬទេ អ្នកស្វែករកញាតិលោហិតក៏ជាផ្នែកមួយនៃសារការីផងដែរ ហើយជាអ្នកពិនិត្យថាសន្តតិជនស្ថិតនៅលំដាប់ទីប៉ុន្មានដែលអនុលោមតាមច្បាប់ Intestate Law របស់ប្រទេសបារាំង ក្នុងករណីមិនមានមតកសាសន៍។ម្យ៉ាងទៀត ដើម្បីធ្វើការអះអាងថាខ្លួនជាសន្តតិជន គឺត្រូវសុំឲ្យសារការីចេញលិខិតបញ្ជាក់អត្តសញ្ញាណថាពិតជាសន្តតិជនពិតប្រាកដមែន[59]។ បានន័យថា ប្រទេសនីមួយៗអ្នកអនុវត្តនីតិវិធីទាក់ទងនឹងរបបសន្តតិកម្មមិនមែនមានតែតុលាការមួយនោះទេ គឺ មានមេធាវី ឬ សារការីក៏មានតួនាទីយ៉ាងសំខាន់ដែលអាចជួយក្នុងការអនុវត្តនីតិវិធីដូចតុលាការដែរ គឺអាស្រ័យទៅតាមបទដ្ឋានគតិយុត្តនៃប្រទេសនីមួយៗ។

[58] Cori A. Robinson, *The Office Of The Public Administrator: An Important Government Office, Albeit One You Hope To Never Have To Use*, https://abovethelaw.com/2019/03/the-office-of-the-public-administrator-animportant-government-office-albeit-one-you-hope-to-never-have-to-use/?fbclid=IwAR1bxONVxH7YNiOmh5Kge - NaiD2EYh85xMSYY3Qrq2KEddmz_NqLqDAxdFc,(ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

[59] *Succession in France*, http://www.successions-europe.eu/Questions.aspx?c=fr , (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើនេះរួចមក យល់ឃើញថាក្រសួងយុត្តិធម៌គួរតែផ្ទេរសមត្ថកិច្ចស្វែងរកសន្តតិជនពីតុលាការឲ្យទៅសារការី ព្រោះតុលាការពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចការនេះឲ្យបានល្អប្រសើរទៅតាមនីតិវិធីនោះទេ។ តុលាការមានភាពមមាញឹកនៅក្នុងតួនាទីរបស់ខ្លួនក្នុងការវិនិច្ឆ័យ និង កិច្ចការផ្សេងៗទៀត ដូចនេះហើយប្រសិនបើសារការីទទួលការងារនេះនឹងមានភាពល្អប្រសើរជាង ពីព្រោះសារការីជាអ្នកធ្វើលិខិតយថាភូត និង កិច្ចការធ្វើបណ្តាំមតិកដែលមានសមត្ថកិច្ចទូទាំងប្រទេស ជាហេតុនាំឲ្យសារការីអាចធ្វើកិច្ចការងារនេះបានលឿនរហ័សជាង និង ប្រសិទ្ធិភាពខ្ពស់ទៅតាមច្បាប់បានកំណត់។ ម៉្យាងទៀតតុលាការមានសមត្ថកិច្ចតែស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ជាហេតុធ្វើឲ្យពិបាកក្នុងការស្វែងរកសន្តតិជនឃើញ ការងារនេះមានតែសារការីដែលសាកសមនឹងធ្វើជំនួសតុលាការ។

លើសពីនេះទៅទៀត រយៈពេលនៃការស្វែងរកសន្តតិជនដែលមានចែងក្នុងច្បាប់ពុំគ្រប់គ្រាន់ឡើយ ព្រោះរយៈពេលទាំងនេះពុំអាចរៀបចំ និង ស្វែងរកសន្តតិជនឃើញឡើយ ការរកសន្តតិជនមិនមែនជាការងាយស្រួលនោះទេ ដូច្នេះគួរតែបន្ថែមរយៈពេលឲ្យវែងជាងនេះដើម្បីស្វែងរកសន្តតិជនឲ្យមានប្រសិទ្ធិភាព និង ច្បាស់លាស់កុំឲ្យមានការភ័ន្តច្រឡំ ជាពិសេសពិបាកនឹងជឿថាជននោះពិតជាសន្តតិជនពិតប្រាកដមែនគួរតែពិនិត្យមើលលើភស្តុតាងឲ្យបានច្បាស់ និង មានការត្រួតពិនិត្យប្រុងប្រយ័ត្នជាងនេះ ដោយការធ្វើតេស្ត DNA ឬ ការធ្វើកោសល្យវិច័យបន្ថែមលើរាងកាយជាដើម ព្រោះឯកសារមួយចំនួនបុគ្គលអាចធ្វើការកែប្រែ ឬ ក្លែងបន្លំបានប្រសិនបើតុលាការមិនបានត្រួតពិនិត្យបានល្អិតល្អន់អាចធ្វើឲ្យបាត់បង់ដល់ផលប្រយោជន៍របស់សន្តតិជនពិតប្រាកដដែលមិនគួរមើលរំលង។ សារការីគួរតែមានកិច្ចសហប្រតិបត្តិការជាមួយមន្រ្តីជំនាញដើម្បីធ្វើកោសល្យវិច័យឲ្យបានច្បាស់លាស់ ចំណែកឯបន្ទុកក្នុងការចំណាយទៅលើសហប្រតិបត្តិការទាំងអស់គួរតែត្រូវជាចំណែកមួយភាគនៃមតិកនៅពេលដែលកិច្ចការក្នុងការស្វែងរកសន្តតិជនត្រូវបានជោគជ័យជាស្ថាពរ។

មួយវិញទៀត ក្រសួងយុត្តិធម៌គួរតែបង្កើតគំរូអំពីព្រឹត្តិបត្រ ព្រមទាំងលិខិតគំរូផ្សេងៗដែលទាក់ទងនឹងការស្វែងរកសន្តតិជន ព្រោះសព្វថ្ងៃនេះពុំទាន់មានគំរូព្រឹត្តិបត្រប្រកាសរកសន្តតិជនជាក់លាក់នៅឡើយទេ ដូចនេះត្រូវមានគំរូព្រឹត្តិបត្រ និង គំរូលិខិតទាំងអស់ឲ្យបានត្រឹមត្រូវចៀសវាងនាំឲ្យមានភាពខុសគ្នានៃលិខិតទាំងនោះរវាងសាលាដំបូងនីមួយៗ។ ជាចុងក្រោយ ដោយហេតុថាការរកសន្តតិជនមានភាពខ្វះចន្លោះ ដូចនេះក្រសួងយុត្តិធម៌ដែលជាស្ថាប័នទទួលបន្ទុកគួរតែរៀបចំឡើងវិញឲ្យមានប្រសិទ្ធិភាពខ្ពស់ជាងនេះ ដើម្បីកុំឲ្យមានភាពលំអៀងក្នុងរបបសន្តតិកម្ម៕

# ឯកសារយោង

# ឯកសារយោង

❖ **កម្រងច្បាប់**


- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
- ក្រឹត្យលេខ០១ ក្រ ចុះថ្ងៃទី២៥ខែមិថុនា ឆ្នាំ១៩៨១។
- ក្រឹត្យលេខ១៤ ក្រ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៩។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។


❖ **សៀវភៅដែលបានបោះពុម្ពផ្សាយ**


- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី. ២០១០. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦៖ គន្លឹះទី៨-ទី៩.*
  ភ្នំពេញ៖ ការិយាល័យកម្មវិធីអភិវឌ្ឍផ្នែកច្បាប់ និង យុត្តិធម៌នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា។
- ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. ២០១៧. *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ៣.*
  ភ្នំពេញ៖ គម្រោងអភិវឌ្ឍវិស័យច្បាប់ និង តុលាការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA)។
- ទី ជីហួត.២០០៤. *រឿងតេជោយ៉ត.* បោះពុម្ពលើកទី២. ភ្នំពេញ៖ ស្រី ប៊ុនជន។
- បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើមដោយគ្រឹះស្ថានបោះពុម្ព និង ចែកចាយនៃក្រសួងអប់រំ យុវជន និង កីឡា. ២០០១. *ប្រជុំរឿងព្រេងខ្មែរ ភាគទី៤.* ភ្នំពេញ៖ អប់រំ។
- រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត. ២០១៧. *នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ.* ភ្នំពេញ៖ ជោគជ័យ។
- វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត។
- ហែល ចំរើន. *វិវាទដីធ្លីនៅកម្ពុជា.* រកបាននៅសៀវភៅ វស្សបវត្តិ ២០០៧. បោះពុម្ពផ្សាយដោយការឧបត្ថម្ភពីក្រុមសហប្រតិបត្តិការសកម្មភាពវប្បធម៌របស់ស្ថានទូតបារាំង ។
- អម សុផាណារ៉ាត. *នីតិរដ្ឋប្បវេណី.* មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំសិក្សា២០១៥-២០១៦។

❖ សារណាបញ្ចប់ការសិក្សា

- គង់ ស៊ីម៉េង និង វ៉ាន់ សម្បស្ស. ២០១៨. សន្តតិកម្មសម្រាប់អនីតិជន. សារណាថ្នាក់បរិញ្ញាបត្រ. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។
- គឹម រតនា និង សុខ សិមួយ. ២០១៦. ចំណែកមត៌ក និង ការសម្រួលចំណែកមត៌ក. សារណាថ្នាក់បរិញ្ញាបត្រ. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

❖ គេហទំព័រ

- អ៊ីវ ប៉ូលី. ២០១៥. *ការបែងចែកមត៌ក.* អាចរកបាននៅ https://www.jica.go.jp/project/english/cambodia/025/materials/c8h0vm0000c54sbnatt/code_03_02.pdf (ចូលទស្សនាថ្ងៃទី០៥ មេសា ២០១៩)។
- Cori A. Robinson. *The Office Of The Public Administrator: An Important Government Office, Albeit One You Hope To Never Have To Use.* https://abovethelaw.com/2019/03/the-office-of-the-public-administrator-an-important-government-office-albeit-one-you-hope-to-never-have-to-use/?fbclid=IwAR1bxONVxH7YNiOmh5KgeNaiD2EYh85xMSYY3Qrq2KEddmz_NqL_qDAxdFc. (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។
- David Shulman. *Man Dies With $40 Million, No Will, And No Heirs.* https://www.ginsbergshulman.com/blog/40milnowil/?fbclid=IwAR17djhODlo0qIqaUTUuRB3OaB_656MhtAw3xwIHMZj5q_qRKUDv5sBxe5A. (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។
- Jason W. Stern. *What Happens When A Holocaust Survivor Dies With $40,000,000.00, No Will Or Known Living Relatives? Kinship Dilemma; Estate Of Roman Blum.* http://www.queensestatelaw.com/2013/05/01/what-happens-when-a-holocaust-survivor-dies-with-40000000-00-no-will-or-known-living-relatives-kinship-dilemma-estate-of-romanblum/?fbclid=IwAR3FNgRbG0q5u_WeHcUISA5ZfzVu6EiLXni9vumJUafUCqYt5VyE8Ef4S P8. (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)
- *Succession in France*, http://www.successions-europe.eu/Questions.aspx?c=fr, (ចូលទស្សនាថ្ងៃទី១០ មេសា ២០១៩)។

# ឧបសម្ព័ន្ធ

# លំហូរនៃនីតិវិធី

## លំហូរនៃនីតិវិធី

ការជ្រើសតាំងអ្នកគ្រប់គ្រង (មាត្រា ១២៩១-១)

ការជូនដំណឹងជាសាធារណៈលើកទី១(មាត្រា១២៩១-២)

យ៉ាងហោចណាស់ ២ខែ (មាត្រា ១២៩៦-១)

ការជូនដំណឹងជាសាធារណៈលើកទី២ (មាត្រា១២៩៦-១)

យ៉ាងហោចណាស់ ២ខែ (មាត្រា ១២៩៦-១)

ការដកចេញពីការជម្រះ (១២៩៦-២ និង ១២៨៨)

---

ការចាប់ផ្តើមការជម្រះនៃមតិក (មាត្រា ១២៩៦-២ និង ១២៨៣ ដល់ ១២៨៦)

ការជូនដំណឹងជាសាធារណៈលើកទី៣ (មាត្រា ១២៩៧)

យ៉ាងហោចណាស់ ៦ខែ (មាត្រា ១២៩៧-១)

**អត្ថិភាពនៃសន្តតិជន**

លក្ខណៈនៃអត្ថិភាព

លក្ខណៈសម្បត្តិជាសន្តតិជន (បុគ្គលដែលមានជីវិតរស់នៅ និង បុគ្គលដែលមិនផ្តាច់សិទ្ធិជាសន្តតិជន)

បុគ្គលមានសិទ្ធិជាសន្តតិជន (សន្តតិជនតាមច្បាប់ សន្តតិជនជំនួស សន្តតិជនជាសហាព័ទ្ធ)

ការទទួលស្គាល់សន្តតិកម្ម (ការយល់ព្រមទាំងស្រុង និង ការយល់ព្រមដោយកម្រិត)

រលត់សិទ្ធិអ្នកគ្រប់គ្រង

**នត្ថិភាពនៃសន្តតិជន**

លក្ខណៈនៃនត្ថិភាព

ការបាត់បង់សិទ្ធិជាសន្តតិជន (បុគ្គលដែលផ្តាច់សិទ្ធិជាសន្តតិជន)

ការបោះបង់សន្តតិកម្ម

មិនរលត់សិទ្ធិអ្នកគ្រប់គ្រង

ការចាត់ចែងមតិក (កម្រៃសម្រាប់អ្នកគ្រប់គ្រង ជនមានិស្ស័យពិសេស និង ធ្លាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ)

# មាត្រានៃក្រមរដ្ឋប្បវេណីនៃ
# ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
# ដែលធាក់ទង

# អត្ថបទបរទេស

# WHAT HAPPENS WHEN A HOLOCAUST SURVIVOR DIES WITH $40,000,000.00, NO WILL OR KNOWN LIVING RELATIVES? KINSHIP DILEMMA; ESTATE OF ROMAN BLUM





1 By Jason Stern 0 Comments

As a New York estate lawyer, practicing in Forest Hills, New York, I can tell you sooner or later a relative of every single person in the entire world passes through Queens at some point. With a borough this populated in a City this expansive it is no wonder that there are more people who pass away in Queens than in any other part of the country. By the numbers alone, despite my best efforts as a NY estate lawyer, many of these people will pass without a will.

**However, what happens when someone passes away without a will or known relatives and leaves behind 40 Million Dollars?**

What happens is, the estate becomes a NY kinship case. A NY kinship case occurs when a decedent passes without a will, close surviving relatives and when the nearest relative is a distant cousin. In such instances in NY, the body of law governing NY kinship cases dictates how the proceeds of such an estate are to be distributed.

The kinship law in NY is a highly technical, complex array of statutes, case law and genealogical research that is required to prove up kinship. This area of law is occupied by highly specialized NY kinship lawyers who are well versed and experienced in these types of matters. Quite simply, if you do not have the right NY kinship lawyer, you will be waiting a very long time to collect the proceeds from this type of estate.

**Who was Roman Blum?**

We think Roman Blum was born near Warsaw Poland on September 15, 1914. I say think because as history would have it, Poland was invaded by Nazi Germany on September 1, 1939 in what has since become known as the Blitzkrieg. And so began the tyrannous occupation and persecution of Poland that spanned nearly seven long years costing tens of millions of lives and wreaking a trail of havoc and destruction the likes of which the world has not forgotten. Included in those losses were the birth, marriage and death records of more than 20 million murdered and displaced victims, many of them Jews. After losing his wife and son in The Buchenwald Concentration Camp, Roman survived the harsh conditions of the camp and was liberated in May of 1945.

After losing his wife and son in the holocaust, Roman Blum met a woman Eva in Frankfurt whom he married and came to America with. In 1949, Roman and Eva Blum settled down in Forest Hills, New York. A successful builder, Roman Blum figured out before the Verrazano Narrows Bridge was built, that it would cause a huge windfall in real estate prices in Staten Island. As a natural entrepreneur, Roman relocated to Staten Island New York (http://www.nytimes.com/glogin?URI=http://www.nytimes.com/2013/04/28/nyregion/holocaust-survivor-left-an-estate-worth-almost-40-million-but-no-heirs.html&OQ=pagewantedQ3DallQ26ampQ3B_rQ3D0Q26_rQ3D0&OP=6528e038Q2F)F3p)8-p)Q3CQ3CQ3C)Q2Bp1Q7C)PFGKVFFpD)DbQ25m)b,)D.)8-VQ3EgcF8)Q2BFQ7CFGCUKp9KUVQ60cQ60FV9Q7CQ3Eyp9C89Q3EKpCpQ3E9Q3CFVpQ2B9CQ7C1FKp9,b91cQ his wife where he amassed a substantial fortune in real estate.

Roman and his wife Eva never had children. In 1992, Roman lost his second wife. With the passing of his second wife, Roman was left with no known surviving heirs. In January of 2012, at the age of 97 years old, Roman Blum died in the Staten Island University Hospital. Roman Blum passed without a will, no known surviving relatives and $40 Million Dollars in cash and assets. His body laid in the morgue for 4 days until his lawyer claimed the body.

**What happens to the $40 Million Dollars?**

Had Roman Blum executed a simple will for $300, his entire $40,000,000.00 estate would have been distributed to the designated beneficiaries and or charities of his choosing. However since he died intestate, without a will, the amount will either go to surviving heirs if any exist or to the State of New York.

Initially the attorney for the public administrator’s office for the borough of Staten Island does a detailed inventory of any and all assets of the estate. Once inventoried, which could take a substantial amount of time in a large estate such as this one, the public administrator’s office will search for any and all surviving relatives. At this point, as a NY kinship lawyer, this is when the surviving heirs would retain our firm to prove their relationship to the decedent. As their NY kinship lawyer, our office would conduct an exhaustive search of official records, witness statements from friends and family, and in this case perhaps go to Europe to find additional witnesses and documentation.

In this particular NY kinship estate, I can tell you it will be a very complex and lengthy process. Already a year has passed and neither the attorney for the public administrator nor any other NY kinship lawyer has come forward with any evidence of surviving heirs. These types of NY kinship cases are the hardest to prove as most of the vital records required to either locate or prove kinship were lost and destroyed in the War. Without such vital records and the existence of any immediate family it is unlikely that any heirs will be located. Additionally, since Roman Blum was 97 years of age, it is unlikely that any of his heirs would still be alive to claim title to his estate.

That’s not to say that this estate cannot be claimed. Having handled numerous complicated NY estates similar to this one, our firm has used various international organizations around the world to obtain these elusive vital statistics and records. Many of these organizations have extensive resources and have been compiling vital statistics through the years in an effort to recreate much of the information that was lost.

However, should no surviving heirs come forward to claim this estate, it becomes increasingly likely with each passing day that the proceeds of Roman Blum’s $40,000,000.00 estate will eventually revert to the State.

If you or a family member would like to speak with a NY estate lawyer at the Law Offices of Jason W. Stern & Associates about a kinship or any other estate matter, feel free to call us at (718) 261-2444 for a free consultation.

SMALL LAW FIRMS

# The Office Of The Public Administrator: An Important Government Office, Albeit One You Hope To Never Have To Use

Who will be the executor for your estate? Make the hard decisions and ask the difficult questions now, to save grief later.

By CORI A. ROBINSON

Mar 19, 2019 at 5:01 PM



A former employee of the Kings County (New York) Public Administrator's Office has been sentenced to 60 days in jail and five years of probation after pleading guilty for stealing $78,000 from eight Brooklyn estates. Fitzroy Thompson pleaded guilty to second-degree larceny on January 9, 2019. He has also been ordered to pay back the monies to the Estate by the end of his probation.

The Thompson investigation revealed that between July 2017 and April 2018, he used estate credit cards and checking to make his personal purchases and payments including more

A public administrator is a civil servant who is charged with administering a decedent's affairs when she dies without a last will and testament or any known relatives who are able or willing to serve as administrator of the estate. Generally, each county has its own public administrator who employs a staff to help marshal, safeguard, and distribute its residents' estates. Often public administrators will serve as estate fiduciaries until relatives are located and they may continue to do so if the family is unwilling. As such, the public administrator is often the first to enter a decedent's residence upon her passing to search for a last will and testament and to immediately safeguard any personal or financial assets. A public administrator may also control the remains of the deceased when there are no other known agents. This means that the public administrator chooses the decedent's final resting place and the method of internment.

Indeed the public administrator is an important and necessary office in any society. Countless individuals die without wills, close family, or any instructions, and the Public Administrator provides care, organization, and hopefully closure for the deceased and any located family. It is, however, an office you hope to never have to use, and so it would behoove all individuals to take care of their personal matters before they die, lest the county review, marshal, and control your life, after death.

Part of executing estate planning documents is choosing which of your friends and family members you wish to serve as your fiduciaries. One should carefully contemplate the best candidates for executor, trustee, agent under a power of attorney, and agent under a health care proxy. Efficiency, diligence, and honesty are qualities one seeks when appointing any of these fiduciaries. Often emotional reasons are used to choose an agent, despite financial and organizational capabilities. If this is the case, an agent may retain the services of an account or an attorney for assistance.

Sometimes there is no one to serve, either by choice or consequence. It is not uncommon for clients to reveal no individuals whom they are close enough with to charge with handling their affairs, while alive or deceased. This may be because they do not have any close relatives or because they are estranged from family. At times, there are no friends who care to step in when family cannot or the client does not wish to ask an individual for fear of burdening him. This is a frequent issue amongst the elderly who often become isolated as

For many reasons, including guardianship of children, management of assets, and beneficiaries, it is imperative for one to execute a last will and testament. Some clients may procrastinate executing a will because they do not have an individual serve as executor. While beneficiaries may be easier to choose, serving as an executor may be seen as a burden. Executorship takes time and effort, however, one is compensated for her time with statutory commissions. In the event one dies without a last will, her estate will pass via intestate laws. This also means that the court will look to next of kin to serve as the administrator of the decedent's estate. As a result of failing to execute a last will, not only will the estate be distributed to family members who may be remote as distant cousins, but those individuals will be asked to serve as the administrators of the estate. When there is no one willing or suitable to serve, the public administrator serves. This means that the public administrator could not locate even the most remote relative who was willing or qualified to serve.

Clients should be encouraged to reach out to family, friends, and even service providers such as accountants and attorneys to inquire as to their willingness to serve on their behalf. Often individuals are afraid to ask, which is understandable considering the gravity of the situation. Undisputedly, one's estate becomes more complicated and expensive to administer when a public administrator is appointed. In order to avoid the added difficulties and unintentional consequences, we should all be encouraged to make the hard decisions and ask the difficult questions now, to save grief later.

---

***Cori A. Robinson is a solo practitioner having founded Cori A. Robinson PLLC, a New York and New Jersey law firm, in 2017. For more than a decade Cori has focused her law practice on trusts and estates and elder law including estate and Medicaid planning, probate and administration, estate litigation, and guardianships. She can be reached at cori@robinsonestatelaw.com.***